

# ការវាយតម្លៃភាពក្រីក្រ

## សម្រាប់សហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ

របាយការណ៍ចេញផ្សាយ ខែកុម្ភៈ ឆ្នាំ២០២២

អង្គការសមាគមធាងត្នោត
Sahmakum Teang Tnaut Organization • a Cambodian Urban NGO

# អង្គការសមាគមធាងត្នោត

អង្គការសមាគមធាងត្នោត(STT)ត្រូវបានបង្កើតក្នុងឆ្នាំ២០០៥និងត្រូវបានចុះបញ្ជីជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជួយគាំទ្រដល់សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញនៅឆ្នាំ២០០៦។ អង្គការសមាគមធាងត្នោតចាប់ផ្តើមជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលផ្តោតលើការជួយលើកកម្ពស់ផ្នែកបច្ចេកទេសដល់សហគមន៍ក្រីក្រ និងបន្ទាប់មកលូតលាស់ខ្លួន ដោយផលិតជាផែនទីសហគមន៍ក្រីក្រ ការសិក្សាស្រាវជ្រាវ និងការតស៊ូមតិ ដើម្បីសម្រេចគោលដៅរបស់ខ្លួនក្នុងការជួយដល់សហគមន៍ក្រីក្រ និងងាយរងគ្រោះឱ្យទទួលបានសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន។

**ការស្រាវជ្រាវទទួលបានមូលនិធិគាំទ្រដោយៈ**

HEINRICH BÖLL STIFTUNG
PHNOM PENH
Cambodia

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**

ទូរស័ព្ទលេខៈ (+៨៥៥) ២៣ ៥៥៥ ១៩៦៤

អ៊ីម៉ែលៈ info@teangtnaut.org

គេហទំព័រៈ www.teangtnaut.org

ហ្វេសប៊ុកៈ https://www.facebook.com/sttcambodia

ធ្វីទ័រៈ https://twitter.com/STTCambodia



# ទីតាំងសហគមន៍ក្រីក្រក្នុងទីក្រុង

ស្ថានភាពរស់នៅរបស់ប្រជាសហគមន៍ក្រីក្រនៅប្រឡាយបឹងត្របែកភូមិ៤នាពេលបច្ចុប្បន្ន

# បញ្ជីពាក្យកាត់

| | |
|---|---|
| EBA | ប្រព័ន្ធអនុគ្រោះពន្ធលើផលិតផលគ្រប់យ៉ាងលើកលែងតែអាវុធ |
| EU | សហភាពអឺរ៉ុប |
| FGD | ការពិភាក្សាជាក្រុម |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GSP | ប្រព័ន្ធអនុគ្រោះទូទៅ |
| HHS | ការស្ទង់មតិតាមគ្រួសារ |
| MoT | ក្រសួងទេសចរណ៍ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| SUPF | សម្ព័ន្ធអ្នកតាំងទីលំនៅក្រីក្រក្នុងទីក្រុង |
| STT | អង្គការសមាគមធាងត្នោត |
| TOR | លក្ខខណ្ឌយោង |
| UNICEF | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| WB | ធនាគារពិភពលោក |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក |

# មាតិកា


ខ្លឹមសារសង្ខេប..........១
១. សេចក្តីផ្តើម..........៥
២. នគរូបនីយកម្ម៖ ស្ថានភាពបរិបទ និងនិន្នាការ..........៧
៣. សហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ៖ និន្នាការ និងបញ្ហាប្រឈមនាពេលអនាគត..........៨
៤. គោលបំណងនៃការសិក្សា..........៩
៥. វិធីសាស្រ្ត..........១០
៦.វិសាលភាព និងដែនកំណត់..........១២
៧. តំបន់គោលដៅសម្រាប់ការសិក្សានេះ..........១៣
៨. ការរកឃើញសំខាន់ៗ..........១៥
ក.សាវតាររបស់អ្នកចូលរួមផ្តល់បទសម្ភាស..........១៥
ខ. ស្ថានភាពសង្គម-សេដ្ឋកិច្ចក្នុងគ្រួសារ..........១៩
គ. លំនៅឋាន..........២៥
ឃ.ឯកសារគ្រួសារ..........២៧
ង. ការទទួលបានសេវាថែទាំសុខភាព..........២៩
ច. ការអប់រំរបស់កុមារ..........៣៣
ឆ. ភាពងាយរងគ្រោះនៅក្នុងគ្រួសារ..........៣៦
ជ. អនាម័យ និងអនាម័យខ្លួនប្រាណ..........៤០
ឈ. ទ្រព្យសម្បត្តិរបស់ក្រុមគ្រួសារ..........៤៤
ញ. លទ្ធភាពទទួលបានអគ្គិសនីរបស់សហគមន៍..........៤៥
ដ.ថាមពលសម្រាប់ចម្អិនអាហារ..........៤៥
៩. សេចក្តីសន្និដ្ឋាន..........៤៦
១០. អនុសាសន៍..........៤៧
១១. ឧបសម្ព័ន្ធ..........៤៨

# បញ្ជីតារាង


តារាងទី ១៖ បញ្ជីឈ្មោះសហគមន៍ដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ....................១៣
តារាងទី ២៖ កម្រិតនៃការអប់រំរបស់អ្នកចូលរួមផ្តល់បទសម្ភាស....................១៦
តារាងទី ៣៖ ប្រភេទចំណូលរបស់អ្នកចូលរួមផ្តល់បទសម្ភាស....................១៩
តារាងទី ៤៖ ការបាត់បង់ចំណូលពីការងារក្នុងអំឡុងពេលជំងឺកូវីដ-១៩....................២០
តារាងទី ៥៖ កម្រិតចំណូលក្នុងមួយខែនៅក្នុងអំឡុងពេលផ្ទុះឡើងនៃជំងឺកូវីដ-១៩....................២១
តារាងទី ៦៖ ទីតាំងគ្រួសារនៅក្នុងសហគមន៍....................២២
តារាងទី ៧៖ មូលហេតុនៃការខ្ចីប្រាក់....................៣៩

# បញ្ជីក្រាហ្វិច


ក្រាហ្វិចទី ១៖ ភេទរបស់អ្នកចូលរួមផ្តល់បទសម្ភាស.....១៥
ក្រាហ្វិចទី ២៖ អាយុរបស់អ្នកចូលរួមផ្តល់បទសម្ភាស.....១៥
ក្រាហ្វិចទី ៣៖ ស្ថានភាពគ្រួសារ.....១៦
ក្រាហ្វិចទី ៤៖ រយៈពេលនៃការរស់នៅក្នុងសហគមន៍.....១៧
ក្រាហ្វិចទី ៥៖ ទំនាក់ទំនងក្នុងក្រុមគ្រួសារ.....១៧
ក្រាហ្វិចទី ៦៖ អ្នករកចំណូលនៅក្នុងគ្រួសារមុនជំងឺកូវីដ-១៩.....១៩
ក្រាហ្វិចទី ៧៖ ភាគរយនៃអ្នកចូលរួមផ្តល់បទសម្ភាសអំពីការបាត់បង់ការងារបន្ទាប់ពីមានជំងឺកូវីដ.....២០
ក្រាហ្វិចទី ៨៖ ចំនួនសមាជិកគ្រួសារដែលបានបាត់បង់ការងារអំឡុងពេលជំងឺកូវីដ-១៩.....២០
ក្រាហ្វិចទី ៩៖ ចំណូលគ្រួសារដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩.....២១
ក្រាហ្វិចទី ១០៖ ការផ្លាស់ទីលំនៅរបស់គ្រួសារក្នុងអំឡុងពេល ៥ឆ្នាំកន្លងមក.....២២
ក្រាហ្វិចទី ១១៖ តើគ្រួសារបានផ្លាស់ប្តូរផ្ទះសម្បែងរបស់ពួកគេញឹកញាប់ប៉ុនណាក្នុងអំឡុងពេល ៥ឆ្នាំកន្លងមកនេះ?.....២២
ក្រាហ្វិចទី ១២៖ ហេតុផលនៃការផ្លាស់ទីលំនៅ (សម្រាប់ការផ្លាស់ទីលំនៅលើកចុងក្រោយតែប៉ុណ្ណោះ).....២៣
ក្រាហ្វិចទី ១៣៖ ស្ថានភាពស្នាក់នៅរបស់អ្នកចូលរួមផ្តល់បទសម្ភាស.....២៥
ក្រាហ្វិចទី ១៤៖ ប្រភពប្រាក់សម្រាប់សាងសង់លំនៅឋាន.....២៥
ក្រាហ្វិចទី ១៥៖ ស្ថានភាពលំនៅឋានរបស់គ្រួសារ.....២៥
ក្រាហ្វិចទី ១៦៖ ទំហំ ឬទីកន្លែងក្នុងលំនៅឋាន.....២៥
ក្រាហ្វិចទី ១៧៖ តើគ្រួសារអ្នកមានសៀវភៅគ្រួសារដែរឬអត់?.....២៧
ក្រាហ្វិចទី ១៨៖ មូលហេតុដែលមិនមានសៀវភៅគ្រួសារ.....២៧
ក្រាហ្វិចទី ១៩៖ តើអ្នកមានសៀវភៅស្នាក់នៅដែរឬអត់?.....២៧
ក្រាហ្វិចទី ២០៖ គ្រួសារមានកូនអាយុក្រោម ១២ខែ.....២៩
ក្រាហ្វិចទី ២១៖ តើក្មេងទាំងនេះបានចាក់វ៉ាក់សាំងហើយឬនៅ?.....២៩
ក្រាហ្វិចទី ២២៖ តើនៅរក្សាទុកកាតលឿងក្នុងគ្រួសារដែរឬទេ?.....២៩
ក្រាហ្វិចទី ២៣៖ តើមានស្ត្រីមានផ្ទៃពោះក្នុងគ្រួសារដែរឬទេ?.....២៩
ក្រាហ្វិចទី ២៤៖ ភាពញឹកញាប់នៃការទៅមណ្ឌលសុខភាពរបស់ស្ត្រីមានផ្ទៃពោះ.....៣០
ក្រាហ្វិចទី ២៥៖ តើស្ត្រីមានផ្ទៃពោះទាំងនេះទៅពិនិត្យសុខភាពនៅកន្លែងណា?.....៣០
ក្រាហ្វិចទី ២៦៖ តើអ្នកបានចាក់វ៉ាក់សាំងការពារមេរោគកូវីដ-១៩ ហើយឬនៅ?.....៣០
ក្រាហ្វិចទី ២៧៖ តើអ្នកបានចាក់វ៉ាក់សាំងការពារមេរោគកូវីដ-១៩ ប៉ុន្មានដងហើយ?.....៣០
ក្រាហ្វិចទី ២៨៖ មូលហេតុដែលមិនបានចាក់វ៉ាក់សាំងការពារមេរោគកូវីដ-១៩.....៣១
ក្រាហ្វិចទី ២៩៖ គ្រួសារដែលមានក្មេងអាយុពី ៣ ទៅ ៥ឆ្នាំ.....៣៣
ក្រាហ្វិចទី ៣០៖ ក្មេងអាយុពី ៣ ទៅ ៥ឆ្នាំដែលទៅសាលាមត្តេយ្យ.....៣៣
ក្រាហ្វិចទី ៣១៖ ហេតុផលដែលមិនបញ្ជូនក្មេងទៅសាលាមត្តេយ្យ.....៣៣
ក្រាហ្វិចទី ៣២៖ មានក្មេងដែលមានអាយុចន្លោះពី ៦ ទៅ ១១ ឆ្នាំ.....៣៣
ក្រាហ្វិចទី ៣៣៖ កម្រិតនៃកុមារអាយុពី ៦ ទៅ ១១ ឆ្នាំដែលទៅរៀននៅសាលាបឋម.....៣៤

# បញ្ជីក្រាហ្វិច


ក្រាហ្វិចទី ៣៤៖ តើសាលាមួយណាដែលកូនរបស់ពួកគេទៅរៀន?.....................................................................................៣៤
ក្រាហ្វិចទី ៣៥៖ ក្មេងអាយុពី ១២ ទៅ ១៤ ឆ្នាំនៅក្នុងក្រុមគ្រួសារ.........................................................................................៣៤
ក្រាហ្វិចទី ៣៦៖ តើមានក្មេងទៅរៀននៅអនុវិទ្យាល័យ ឬវិទ្យាល័យដែរឬអត់?...............................................................៣៤
ក្រាហ្វិចទី ៣៧៖ ហេតុផលដែលមិនអាចទៅសាលារៀន.........................................................................................................៣៤
ក្រាហ្វិចទី ៣៨៖ តើមានសមាជិកគ្រួសារធ្វើការងារមានហានិភ័យខ្ពស់ឬទេ?...........................................................................៣៦
ក្រាហ្វិចទី ៣៩៖ តើមានក្មេងកំព្រា ឬក្មេងដែលត្រូវបានគេបោះបង់ចោល រស់នៅជាមួយក្នុងគ្រួសារឬទេ?.........................៣៦
ក្រាហ្វិចទី ៤០៖ តើមានក្មេងដែលខ្វះ ឬមានសារជាតិចិញ្ចឹមមិនគ្រប់គ្រាន់ នៅក្នុងក្រុមគ្រួសារអ្នកឬទេ?..........................៣៦
ក្រាហ្វិចទី ៤១៖ តើមានកុមារដែលពិការរាងកាយ និងផ្លូវចិត្ត នៅក្នុងគ្រួសារអ្នកឬទេ?.......................................................៣៧
ក្រាហ្វិចទី ៤២៖ តើអ្នកធ្លាប់ឃើញមានមនុស្សប្រើប្រាស់ថ្នាំញៀននៅក្នុងសហគមន៍របស់អ្នកឬទេ?...............................៣៧
ក្រាហ្វិចទី ៤៣៖ តើមានសមាជិកគ្រួសារមានជំងឺរ៉ាំរ៉ៃឬទេ?...................................................................................................៣៧
ក្រាហ្វិចទី ៤៤៖ ប្រសិនបើមាន តើអ្នកមានទទួលបានសេវាកម្មថែទាំ ឬព្យាបាលឬទេ?.......................................................៣៧
ក្រាហ្វិចទី ៤៥៖ តើគ្រួសាររបស់អ្នកទទួលបានប័ណ្ណសមធម៌ឬទេ?.......................................................................................៣៨
ក្រាហ្វិចទី ៤៦៖ តាមការសង្កេតរបស់អ្នក តើគ្រួសារក្រីក្រទាំងអស់ទទួលបានប័ណ្ណសមធម៌ឬទេ?.................................៣៨
ក្រាហ្វិចទី ៤៧៖ បំណុលក្នុងគ្រួសារ........................................................................................................................................៣៨
ក្រាហ្វិចទី ៤៨៖ លទ្ធភាពសងបំណុល.......................................................................................................................................៣៩
ក្រាហ្វិចទី ៤៩៖ ចំនួនគ្រួសារដែលមានបង្គន់ក្នុងផ្ទះ..................................................................................................................៤០
ក្រាហ្វិចទី ៥០៖ ប្រភេទនៃបង្គន់នៅក្នុងផ្ទះ..............................................................................................................................៤០
ក្រាហ្វិចទី ៥១៖ តើអ្នកបន្ទោរបង់នៅកន្លែងណា (សម្រាប់គ្រួសារដែលមិនមានបង្គន់)?.......................................................៤០
ក្រាហ្វិចទី ៥២៖ ប្រភពទឹកសម្រាប់បរិភោគ និងចម្អិនអាហារនៅក្នុងគ្រួសារ........................................................................៤០
ក្រាហ្វិចទី ៥៣៖ ប្រភពទឹកសម្រាប់បោកគក់ និងងូត...............................................................................................................៤១
ក្រាហ្វិចទី ៥៤៖ ការយល់ឃើញពីគុណភាពទឹកដែលគ្រួសារប្រើប្រាស់...................................................................................៤១
ក្រាហ្វិចទី ៥៥៖ ទឹកសម្រាប់បរិភោគនៅក្នុងគ្រួសារ...............................................................................................................៤១
ក្រាហ្វិចទី ៥៦៖ ស្ថានភាពទឹកជំនន់ចំពោះផ្ទះសម្បែងរបស់គ្រួសារ........................................................................................៤១
ក្រាហ្វិចទី ៥៧៖ តើផ្ទះសម្បែងលិចទឹករយៈពេលយូរប៉ុនណានៅពេលមានទឹកជន់ម្តង?...........................................................៤១
ក្រាហ្វិចទី ៥៨៖ ការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលក្នុងអំឡុងពេលមានទឹកជំនន់.............................................................៤២
ក្រាហ្វិចទី ៥៩៖ មធ្យោបាយធ្វើដំណើរសម្រាប់ក្រុមគ្រួសារ......................................................................................................៤៤
ក្រាហ្វិចទី ៦០៖ សម្ភារៈ ឬឧបករណ៍សម្រាប់ការទំនាក់ទំនង.....................................................................................................៤៤
ក្រាហ្វិចទី ៦១៖ អគ្គិសនីក្នុងផ្ទះសម្បែង..................................................................................................................................៤៥
ក្រាហ្វិចទី ៦២៖ ការប្រើប្រាស់ថាមពលសម្រាប់ចម្អិនអាហារក្នុងគ្រួសារ...................................................................................៤៥

# ខ្លឹមសារសង្ខេប

របាយការណ៍នេះធ្វើការវាយតម្លៃភាពក្រីក្ររបស់សហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ។ ការសិក្សានេះ ទទួលបានការគាំទ្រពីអង្គការសមាគមធាងត្នោត និងសហគមន៍ចំនួន ៤២ ទីតាំង នៅក្នុងរាជធានីភ្នំពេញ។ សហគមន៍ទាំងនេះត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ ព្រោះពួកគេត្រូវបានចាត់ជាសហគមន៍ក្រីក្រនៅក្នុងការស្រាវជ្រាវរបស់អង្គការសមាគមធាងត្នោត។ ការសម្ភាសត្រូវបានធ្វើឡើងជាមួយនឹងគ្រួសារចំនួន ៩៥៨ គ្រួសារ។ ចំនួនអ្នកចូលរួមផ្តល់បទសម្ភាសនេះតំណាងឱ្យ ១៤% នៃចំនួនគ្រួសារសរុបនៅក្នុងសហគមន៍ទាំង ៤២ ដែលបានជ្រើសរើសសម្រាប់ការស្រាវជ្រាវ។

មានការសិក្សាជាច្រើនបានធ្វើឡើង ក្នុងអំឡុងពេល ២០ឆ្នាំកន្លងមកនេះដើម្បីវាយតម្លៃភាពក្រីក្រ និងស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងទីតាំងលំនៅឋានក្រីក្រនៅទូទាំងរាជធានីភ្នំពេញ។ ការសិក្សាទាំងនេះបង្ហាញឱ្យឃើញថាចំនួនសហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ មានការឡើងចុះចាប់តាំងពីឆ្នាំ ១៩៩៧ មក។ ក្នុងឆ្នាំ ១៩៩៧ ទីតាំងលំនៅឋានក្រីក្រមានចំនួន ៣៧៩ទីតាំង ឆ្នាំ ២០០៩ មានចំនួន ៤១០ទីតាំង ឆ្នាំ ២០១៣ មានចំនួន ៣៤០ ទីតាំង និងចុងក្រោយទីតាំងលំនៅឋានក្រីក្រមានចំនួន ២៧៧ គិតត្រឹមឆ្នាំ ២០១៨។ ការស្រាវជ្រាវខ្លះបង្ហាញថាសហគមន៍ក្រីក្រនៅក្នុងទីក្រុងអាចនឹងកើនឡើងម្តងទៀត ដោយសារការធ្វើចំណាកស្រុកពីជនបទមកទីក្រុងដែលបណ្តាលមកពីបំរែបំរួលអាកាសធាតុ ការជំពាក់បំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងជំងឺកូវីដ-១៩។[១]

កង្វះខាតសេវាកម្មចាំបាច់ រួមមានស្ថានភាពផ្លូវមិនល្អ កង្វះទឹកស្អាត និងការមិនមានអគ្គិសនីរដ្ឋប្រើប្រាស់ គឺជាបញ្ហាចម្បងៗដែលសហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញជួបប្រទះ។ របាយការណ៍មួយរបស់សាលារាជធានីភ្នំពេញឆ្នាំ ២០១២ បានរកឃើញថា ៦០% នៃគ្រួសារកំពុងរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ។ ក្នុងឆ្នាំ ២០១៩ ការសិក្សាស្រាវជ្រាវមួយដែលមានឈ្មោះថា "ភាពងាយរងគ្រោះនៅក្នុងរាជធានីភ្នំពេញ" ដែលបានធ្វើឡើងដោយកម្មវិធីស្បៀងអាហារពិភពលោក បានបង្ហាញនូវការវិវឌ្ឍដ៏គួរឱ្យកត់សម្គាល់មួយអំពីលទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការទទួលបានសេវាអគ្គិសនី និងទឹកស្អាត។ ប៉ុន្តែ បញ្ហាផ្សេងទៀតដូចជាបំណុលនៅតែជាបញ្ហាសំខាន់សម្រាប់ប្រជាពលរដ្ឋនៅទូទាំងរាជធានីភ្នំពេញ ដែលបានចូលរួមក្នុងការសិក្សានេះ។

ចំពោះភាពអយុត្តិធម៌ដែលសហគមន៍ក្រីក្រនៅក្នុងទីក្រុងបានជួបប្រទះដូចគ្នានោះ គឺការគំរាមកំហែងពីការបណ្តេញចេញ។ ការសិក្សាស្ទើរតែទាំងអស់បានរាយការណ៍ពីបញ្ហានេះថាជាការរារាំងដ៏ធំមួយដល់សហគមន៍ក្នុងការទទួលបានជីវភាពភាពប្រសើរ និងមានសន្តិសុខក្នុងជីវិតរបស់ពួកគេ។

ទោះជាយ៉ាងនេះក្តី ការសិក្សានេះបានបញ្ជាក់បន្ថែមទៅលើវឌ្ឍនភាព និងបញ្ហាប្រឈមសំខាន់ៗដែលជួបប្រទះដោយសហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ។ បច្ចុប្បន្ននេះ សហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញស្ទើរតែទាំងអស់មានលទ្ធភាពទទួលបានទឹកស្អាត (៨៧%) និងអគ្គិសនីរដ្ឋ (៩៨%)។ ភាពដ៏ល្អប្រសើរមួយក៏ឃើញមានតាមរយៈសមត្ថភាពរបស់ប្រជាពលរដ្ឋក្នុងទទួលបានការថែទាំសុខភាពផងដែរ។ ឧទាហរណ៍ប្រមាណជា ៨២% នៃកុមារក្រោមអាយុ ១២ ខែ បានទទួលការចាក់វ៉ាក់សាំងពេញលេញ ខណៈដែល ៨២% នៃស្ត្រីមានផ្ទៃពោះទទួលបានការពិនិត្យសុខភាពជាទៀងទាត់។ ក្នុងពេលជាមួយគ្នានេះដែរ មានរហូតដល់ ៨៥% នៃអ្នកចូលរួមផ្តល់បទសម្ភាសទទួលបានការចាក់វ៉ាក់សាំងការពារមេរោគកូវីដ-១៩ ក្នុងនោះ ៨៤% បានចាក់វ៉ាក់សាំងចំនួន ពីរលើក ហើយ ១១% បានចាក់ចំនួន ៣ លើក និង៦% ទទួលបានការចាក់វ៉ាក់សាំងតែមួយលើកប៉ុណ្ណោះ។ ភាពល្អប្រសើរចម្បងមួយទៀតក៏មាននៅក្នុងការអប់រំរបស់កុមារផងដែរ ដែលកុមារគ្រប់អាយុស្ទើរតែទាំងអស់បានទៅរៀននៅសាលា (៩០% ចំពោះកុមារអាយុចន្លោះពី ៦ ទៅ ១២ ឆ្នាំ និង ៩៣% ចំពោះ

[១]ទិន្នន័យរបស់អង្គការសមាគមធាងត្នោត

កុមារអាយុចន្លោះពី ១២ ឆ្នាំ ទៅ ១៤ ឆ្នាំ)។

វិវឌ្ឍន៍ដ៏សំខាន់មួយទៀតក៏មានទាក់ទងនឹងលំនៅឋានរបស់គ្រួសារផងដែរ ហើយប្រជាពលរដ្ឋដែលបានចូលរួមក្នុងការសិក្សានេះ ភាគច្រើនមានលំនៅឋានផ្ទាល់ខ្លួន(៧៥%)។ ការរកឃើញនេះអាចបណ្តាលមកពីការជ្រើសរើសមានលក្ខណៈលម្អៀង ដែលបញ្ហានេះនឹងមានការពិភាក្សាបន្ថែមទៀតនៅផ្នែកខាងក្រោម។ លំនៅឋានជាច្រើនត្រូវបានសង្កេតឃើញថាមានសុវត្ថិភាព និងសាងសង់បានល្អ ប៉ុន្តែ ៥០% នៃអ្នកចូលរួមផ្តល់បទសម្ភាសមានផ្ទះឈើ និងដំបូលស័ង្កសី និង ២០% មានផ្ទះធ្វើពីតដ្ឋ។

ទោះបីជាមានភាពប្រសើរឡើងទាំងនេះក្តី បញ្ហាជាច្រើននៅតែបន្តកើតមាន។ ឧទាហរណ៍ សហគមន៍ក្រីក្រនៅក្នុងទីក្រុងជាច្រើនបន្តប្រឈមនឹងហានិភ័យពីការបណ្តេញចេញ ឬរស់នៅក្នុងតំបន់ដែលច្បាប់មិនអនុញ្ញាតឱ្យពួកគេរស់នៅដូចជាការរស់នៅតាមមាត់ទន្លេ ផ្លូវរថភ្លើង និងតាមមាត់បឹង។ ជាការពិតណាស់ ការបណ្តេញចេញដោយបង្ខំ គឺជាការភ័យខ្លាចមួយដែលត្រូវបានរាយការណ៍ដោយសហគមន៍ជាច្រើន។ បញ្ហាក្រីក្រនៅតែមិនទាន់មានភាពប្រសើរ។ គ្រួសារជាច្រើនបន្តរស់នៅយ៉ាងលំបាកជាមួយនឹងប្រាក់ចំណូលទាប និងការជំពាក់បំណុល ខណៈដែលតម្លៃអគ្គិសនី និងប្រេងសាំងនៅតែខ្ពស់ និងបន្តកើនឡើង។ សហគមន៍ក៏បានត្អូញត្អែពីការមិនទទួលបានប័ណ្ណសមធម៌ និងកម្ចីប្រាក់ដើម្បីចំណាយលើថ្លៃថ្នាំពេទ្យ។

ជាចុងក្រោយ បញ្ហាទាំងអស់នេះមានសភាពកាន់តែធ្ងន់ធ្ងរឡើងព្រោះតែកង្វះខាតសកម្មភាពរួមគ្នារបស់សហគមន៍ដើម្បីដោះស្រាយ និងតស៊ូមតិប្រកបដោយប្រសិទ្ធភាព។ កង្វះការចងក្រង និងកៀរគរ សហគមន៍ឱ្យរឹងមាំ ធ្វើឱ្យសកម្មភាពរួមគ្នាប្រកបដោយប្រសិទ្ធភាពនេះមិនអាចកើតឡើងបាន។ អ្នកដឹកនាំសហគមន៍ និងសមាជិកសហគមន៍បាននិយាយថា ពួកគេមិនទាន់ទទួលបានវគ្គបណ្តុះបណ្តាល ឬការគាំទ្រគ្រប់គ្រាន់នៅក្នុងការលើកឡើងពីបញ្ហារបស់ពួកគេទៅកាន់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធិភាពនៅឡើយទេ។ ផ្អែកតាមការរកឃើញនៃការស្រាវជ្រាវនេះអនុសាសន៍សំខាន់ៗមួយចំនួនអាចត្រូវបានផ្តល់ដូចខាងក្រោម៖

## ១. តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល

- **ការតស៊ូមតិរួមគ្នា៖** ផ្អែកលើស្ថានភាពភូមិសាស្ត្ររបស់សហគមន៍ជាច្រើនដែលបានរួមបញ្ចូលទៅក្នុងការសិក្សានេះ គេអាចសន្មតបានថាសហគមន៍ភាគច្រើនមិនអាចបន្តរស់នៅក្នុងទីតាំងរបស់ខ្លួនបានរហូតនោះទេ។ សហគមន៍ទាំងនេះរួមមានដូចជាសហគមន៍ដែលរស់នៅតាមដងផ្លូវ ក្បែរមាត់ទន្លេតាម ផ្លូវរថភ្លើង ជាដើម។ មុននិងក្រោយសហគមន៍ទាំង នេះនឹងត្រូវគេបង្ខំឱ្យផ្លាស់ទីលំនៅថ្មីដើម្បីអភិវឌ្ឍទីក្រុង។ ដូចនេះ ជាអនុសាសន៍អង្គការមិនមែនរដ្ឋាភិបាលគួរជួយដល់សហគមន៍ទាំងនេះជាអាទិភាព និងឱ្យពួកគេទទួលបានព័ត៌មានទាក់ទងនឹងគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល តម្រូវការ និងនីតិវិធីផ្អែកច្បាប់នានា។ បន្ថែមពីនេះទៅទៀត វានឹងជួយឱ្យសហគមន៍ត្រៀមខ្លួនជាស្រេច និងធានាថាការបណ្តេញចេញ ឬការផ្លាស់ទីលំនៅថ្មីត្រូវបានអនុវត្តតាមវិធានការដែលមានតម្លាភាព និងគណនេយ្យភាព។
- **សេដ្ឋកិច្ចគ្រួសារ៖** ដូចដែលការសិក្សានេះបានបង្ហាញ បំណុលគ្រួសារត្រូវបានលើកឡើងថាជាបញ្ហាដ៏សំខាន់មួយរបស់អ្នកចូលរួមផ្តល់បទសម្ភាស។ បំណុលភាគច្រើនកើនឡើងដោយសារទ្រទ្រង់ចំណូលតាមរយៈការធ្វើអាជីវកម្មខ្នាតតូច បញ្ហាផ្នែកសេដ្ឋកិច្ចនេះគួរដោះស្រាយដោយអង្គការមិនមែនរដ្ឋាភិបាលដែលមាន ជំនាញលើផ្នែកសហគ្រិនសង្គម និងអភិវឌ្ឍន៍សហគ្រិនភាពជាជាងដោះស្រាយដោយផ្ទាល់ដោយអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើតែការតស៊ូមតិ។

## ២. ទំនាក់ទំនងជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ

តួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅតែមានសារៈសំខាន់សម្រាប់ឱ្យប្រជាពលរដ្ឋ និងសហគមន៍ សម្តែងអំពីក្តីបារម្ភ និងបញ្ហារបស់ពួកគេទៅកាន់សាធារណៈជន។ ក្នុងករណីនេះ អ្នកដឹកនាំសហគមន៍ត្រូវយល់ដឹងអំពីប្រព័ន្ធផ្សព្វផ្សាយ និងស្ថាប័នសារព័ត៌មានឯករាជ្យទាំងអស់ ហើយធ្វើការទាក់ទង ពួកគេដើម្បីសម្ភាសនៅពេលចាំបាច់។

## ៣. រាជរដ្ឋាភិបាល ឬសាលារាជធានីភ្នំពេញ

ការបណ្តេញចេញដោយបង្ខំជារឿយៗមានពាក់ព័ន្ធនឹងសំណងហិរញ្ញវត្ថុមួយចំនួន ឬការតាំងទីលំនៅថ្មី។ ការសង្កេតជាច្រើនបានបង្ហាញឱ្យដឹងថាដំណើរការទាំងនេះជាទូទៅធ្វើឡើងដោយគ្មានការពិភាក្សាជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ ផ្ទុយទៅវិញតែងតែធ្វើឡើងតាមរយៈការគំរាមកំហែងមិនផ្តល់សំណងអ្វីទាំងអស់ជាជាងការចរចារ និងពិគ្រោះយោបល់ជាមួយសហគមន៍ប្រកបដោយតម្លាភាព និងអភិបាលកិច្ចល្អ។ ការពិគ្រោះយោបល់រវាងសហគមន៍ និងស្ថាប័នរាជរដ្ឋាភិបាលអំពីសំណង និងការតាំងទីលំនៅថ្មី គឺជាអនុសាសន៍មួយ ដើម្បីធានាថាជីវភាពរបស់គ្រួសារដែលរងផលប៉ះពាល់នឹងមិនរងផលលំបាកកាន់តែខ្លាំង ដែលនាំឱ្យពួកគេកាន់តែជំពាក់បំណុល និងធ្លាក់ក្នុងភាពក្រីក្រកាន់តែខ្លាំង។



# ១. សេចក្តីផ្តើម

ក្នុងអំឡុងពេល ២០ ឆ្នាំកន្លងមកនេះ កម្ពុជាមានការរីកលូតលាស់យ៉ាងខ្លាំងផ្នែកសេដ្ឋកិច្ចរបស់ខ្លួន។ ដោយមានកំណើនថេរចំនួន ៧,៧% ក្នុងមួយឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៩៨ ដល់ ឆ្នាំ ២០១៩ មក។ កម្ពុជាបានក្លាយជា "ប្រទេសដែលមានចំណូលមធ្យមកម្រិតទាប" ក្នុងឆ្នាំ ២០១៥ ហើយត្រូវបានគេព្យាករថានឹងក្លាយជា "ប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់" ត្រឹមឆ្នាំ ២០៣០[២]។វិស័យកសិកម្ម វិស័យនាំចេញសម្លៀកបំពាក់ វិស័យសេវាកម្ម និងវិស័យទេសចរណ៍គឺជាឧស្សាហកម្មសំខាន់ៗសម្រាប់វឌ្ឍនភាពផ្នែកសេដ្ឋកិច្ចទាំងនោះ។ វិស័យកសិកម្មតំណាងឱ្យ ២២,៨៤% នៃកំណើនផលិតផលក្នុងស្រុកសរុប ហើយ ៣៤,៦៧% បានមកពីវិស័យឧស្សាហកម្មនាំចេញរួមបញ្ចូលគ្នាទាំងអស់ និងនៅសេសសល់ពីនេះ ៣៦,២១% បានមកពីវិស័យសេវាកម្ម[៣]។

ក្នុងអំឡុងពេលនៃការរីកលូតលាស់សេដ្ឋកិច្ចនេះ និងយោងតាមរបាយការណ៍បច្ចុប្បន្នភាពមួយរបស់ក្រសួងផែនការ (ឆ្នាំ ២០២១) កម្ពុជាទទួលបានជោគជ័យក្នុងការកាត់បន្ថយអត្រានៃភាពក្រីក្រ ពីជិត ៥០% នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ ចុះមកនៅ ១៧,៨% ត្រឹមឆ្នាំ ២០១៩[៤]។ ថ្វីត្បិតតែយ៉ាងនេះក្តី ការស្ទង់មតិផ្នែកសង្គម-សេដ្ឋកិច្ចពីឆ្នាំ ២០១៩-២០២០ ថ្មីៗនេះ បានរកឃើញថាកម្រិតប្រជាពលរដ្ឋដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្របានកើនឡើងជាថ្មីម្តងទៀតដល់ទៅ ១៧,៨% ដោយសារការផ្ទុះ និងរីករាលដាលនៃជំងឺកូវីដ-១៩[៥]។

ការផ្ទុះ និងរីករាលដាលនៃជំងឺកូវីដ-១៩ បានប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ ក្នុងឆ្នាំ ២០២០ ផលិតផលក្នុងស្រុកសរុបបានធ្លាក់ចុះយ៉ាងគំហុកមកត្រឹម ២,២%[៦]។វិស័យទេសចរណ៍បានទទួលផលប៉ះពាល់យ៉ាងខ្លាំងផងដែរ។ មុនពេលមានការផ្ទុះ និងរីករាលដាលនៃជំងឺកូវីដ-១៩ មានក្រុមហ៊ុនក្នុងវិស័យទេសចរណ៍ប្រមាណ ១៥ ៩៩០ បានចុះបញ្ជីជាមួយក្រសួងទេសចរណ៍[៧]។ នៅក្នុងខែឧសភា ឆ្នាំ២០២០ ប្រមាណជា ៥០% នៃក្រុមហ៊ុនទាំងនេះត្រូវបានបិទអាជីវកម្ម[៨]។

វិស័យនាំចេញផលិតផលកាត់ដេរ ក៏ទទួលរងផលប៉ះពាល់ដ៏ធ្ងន់ធ្ងរដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ និងហេតុផលផ្នែកនយោបាយផងដែរ។ នៅក្នុងខែសីហា ឆ្នាំ ២០២០ ក្រោយពីរាជរដ្ឋាភិបាលបានរំលាយចោលគណបក្សប្រឆាំងសំខាន់ សហភាពអឺរ៉ុបបានសម្រេចដកហូតការលើកលែងពន្ធដល់ទៅ ២០% នៃការនាំចេញសម្លៀកបំពាក់ទៅកាន់ប្រទេសក្នុងសហភាពអឺរ៉ុប។ ផលិតផលនាំចេញដែលបានរងផលប៉ះពាល់ដោយសារការកាត់បន្ថយ ឬការដកហូតនេះរួមមានសម្លៀកបំពាក់ ស្បែកជើង ផលិតផលសម្រាប់ធ្វើដំណើរ និងឧស្សាហកម្មស្ករ ដែលអាចមានតម្លៃប្រហែលមួយភាគប្រាំ (១ ពាន់លានអឺរ៉ូ) នៃការនាំចេញប្រចាំឆ្នាំរបស់ប្រទេសកម្ពុជាទៅកាន់សហភាពអឺរ៉ុប[៩]។ ការនាំចេញផលិតផលកាត់ដេរក៏ទទួលផលប៉ះពាល់នៅពេលដែលរោងចក្រជាច្រើនបានបិទអាជីវកម្មដោយសារតែជំងឺកូវីដ-១៩ ឬកង្វះការបញ្ជាទិញពីប្រទេសនាំទំនិញចូល។

---

[២] ធនាគារពិភពលោក ទស្សនៈទៅទូលើប្រទេស ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ https://www.worldbank.org/en/country/cambodia/overview#1

[៣] Statista: កម្ពុជា៖ ចំណែកវិស័យសេដ្ឋកិច្ចក្នុងផលិតផលក្នុងស្រុកសរុប ពីឆ្នាំ ២០១០ ដល់២០២០ បោះពុម្ពដោយ Aaron O'Neill នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ https://www.statista.com/statistics/438728/share-of-economic-sectors-in-the-gdp-in-cambodia/

[៤] ខ្មែរថាមស៍៖ ខ្សែបន្ទាត់ភាពក្រីក្ររបស់កម្ពុជា ធ្វើបច្ចុប្បន្នភាព៖ ១៧,៨% នៃប្រជាជនកម្ពុជាស្ថិតនៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០២១ https://www.khmertimeskh.com/50973518/cambodias-poverty-line-updated-178-percent-cambodians-under-the-poverty-line/

[៥] ខ្មែរថាមស៍៖ ខ្សែបន្ទាត់ភាពក្រីក្ររបស់កម្ពុជា ធ្វើបច្ចុប្បន្នភាព៖ ១៧,៨% នៃប្រជាជនកម្ពុជាស្ថិតនៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០២១ https://www.khmertimeskh.com/50973518/cambodias-poverty-line-updated-178-percent-cambodians-under-the-poverty-line/

[៦] ធនាគារពិភពលោក ទស្សនៈទៅទូលើប្រទេស ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១

[៧] អង្គការមូលនិធិអាស៊ី៖ ពិនិត្យមើលជាថ្មីម្តងទៀតលើការរីករាលដាលនៅកម្ពុជា Rapid-Survey-on-the-Impact-of-Covid-19-on-MSMEs-in-the-Tourism-Sector-and-Households-in-Cambodia ; Cited from MOT (Ministry of Tourism) statistic 2020, https://asiafoundation.org/wp-

[៨] ដូចខាងលើ

[៩] The Diplomat: តើកម្ពុជានឹងយកចិត្តទុកដាក់ផ្តោតលើការងារកសិកម្មខ្នាតតូចឬទេ? អត្ថបទសរសេរដោយ Len Ang ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ https://thediplomat.com/2020/07/will-cambodias-shift-in-focus-to-small-scale-farming-work/

វិស័យកសិកម្មនៅតែមានស្ថិរភាព។ ផលិតផលកសិកម្មប្រមាណ ៤ ២២១ ១៥៣ តោន ត្រូវបាននាំចេញទៅកាន់ទីផ្សារបរទេសក្នុងអំឡុងពេល ១០ ខែដំបូងក្នុងឆ្នាំ ២០២១ ទោះបីជាមានវិបត្តិសកលនៃជំងឺកូវីដ-១៩ ក៏ដោយ។ ផលិតផលទាំងនេះ រួមមានដំឡូងមី គ្រាប់ស្វាយចន្ទី គ្រាប់ពោត ផ្លែចេកស្រស់ ក្រូចថ្លុង ស្វាយ ម្រេច ម្ទេស[១០]។ យោងតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តួលេខនេះបង្ហាញកំណើនចំនួន ៤៧,៧២ %ធៀបទៅនឹងអំឡុងពេលដដែលក្នុងឆ្នាំ ២០២០[១១]។

ទោះបីជាវិស័យកសិកម្ម មិនទទួលផលប៉ះពាល់ខ្លាំងដូចវិស័យផ្សេងទៀតក៏ដោយ កសិករលក្ខណៈគ្រួសារនៅតែជួបការពិបាកដោយសារខ្វះលទ្ធភាពនាំកសិផលរបស់ពួកគេចូលទៅកាន់ទីផ្សារ។ កង្វះលទ្ធភាពទទួលបានព័ត៌មានអំពីទីផ្សារ និងការទិញមិនទៀតទាត់ គឺជាឧសគ្គរារាំងដល់កសិករតូចតាចទាំងនេះ[១២]។

---

[១០] ខ្មែរថាមស៍៖ ការនាំចេញកសិផលរបស់កម្ពុជាកើនដល់ ៤៧ ភាគរយក្នុង ១០ខែដំបូង ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ https://www.khmertimeskh.com/50963305/cambodias-agricultural-exports-up-over-47-percent-in-first-10-months/

[១១] ដូចខាងលើ

[១២] អង្គការទិន្នន័យអំពីការអភិវឌ្ឍ៖ វិស័យកសិកម្មកម្ពុជាអំឡុងពេលជំងឺកូវីដ ១៩ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ https://opendevelopmentcambodia.net/cambodias-agriculture-sector-amid-covid-19/

# ២. នគរូបនីយកម្ម៖ ស្ថានភាពបរិបទ និងនិន្នាការ

អភិវឌ្ឍន៍ទីក្រុងគឺជាកត្តាទាក់ទាញឱ្យមានការធ្វើចំណាកស្រុកពីតំបន់ជនបទមកទីក្រុង។ ភាពក្រីក្រនៅតំបន់ជនបទគឺជាកត្តាជំរុញឱ្យប្រជាពលរដ្ឋមកទីក្រុងដើម្បីស្វែងរកការងារ និងធ្វើឱ្យជីវភាពប្រសើរជាងមុន។ ចំនួនប្រជាពលរដ្ឋនៅទីក្រុងក្នុងប្រទេសកម្ពុជាមានការកើនឡើងរហូតជារៀងរាល់ឆ្នាំ។ ក្នុងឆ្នាំ ១៩៩៥ មានប្រជាពលរដ្ឋចំនួន ១ ៨៤៤ ៦៨៥ នាក់រស់នៅក្នុងតំបន់ទីក្រុង។ នៅ ១០ ឆ្នាំក្រោយ ក្នុងឆ្នាំ ២០០៥ ចំនួនកើនឡើងរហូតដល់ទៅ ២ ៥៤៥ ០៣៣ នាក់។ ត្រឹមឆ្នាំ ២០២០ ដោយមានកំណើនប្រជាពលរដ្ឋនៅក្នុងទីក្រុងលើសពី ៣,២% ក្នុងមួយឆ្នាំ សព្វថ្ងៃនេះប្រជាពលរដ្ឋចំនួន ៤ ០៥១ ៣៤១ ឬប្រមាណមួយភាគបួននៃចំនួនប្រជាពលរដ្ឋសរុប កំពុងរស់នៅក្នុងតំបន់ទីក្រុង[១៣]។

[១៣] The Macrotrends៖ ចំនួនប្រជាជនកម្ពុជាពីឆ្នាំ ១៩៦០ ដល់ឆ្នាំ ២០២០

# ៣. សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ៖ និន្នាការ និងបញ្ហាប្រឈមនាពេលអនាគត

សហគមន៍ក្រីក្រនៅក្នុងទីក្រុងត្រូវបានគេសិក្សាស្រាវជ្រាវអស់ជាង ២០ ឆ្នាំមកហើយនៅរាជធានីភ្នំពេញ។ ការសិក្សាពីមុនមួយត្រូវបានធ្វើឡើងដោយសម្ព័ន្ធសាមគ្គីភាពអ្នកក្រីក្រក្នុងទីក្រុង ស្តីពី "ស្ថានភាពទីតាំងលំនៅឋានក្រីក្រនៅក្នុងរាជធានីភ្នំពេញក្នុងប្រទេសកម្ពុជា" ។ ក្នុងឆ្នាំ ២០០៩ មានការសិក្សាមួយទៀតដោយអង្គការសមាគមធាងត្នោត ដែលមានចំណងជើងថា "ការស្ទង់មតិក្នុងខណ្ឌទាំង ៨" ដែលពង្រីកបន្ថែមពីលើរបាយការណ៍របស់សម្ព័ន្ធសាមគ្គីភាពអ្នកក្រីក្រក្នុងទីក្រុង។ ក្នុងឆ្នាំ ២០១២ និងឆ្នាំ ២០១៣ មានការសិក្សាវាយតម្លៃពីរទៀតដែលធ្វើឡើងដោយសាលារាជធានីភ្នំពេញដែលមានចំណងជើងថា "ការវាយតម្លៃភាពក្រីក្រក្នុងរាជធានីភ្នំពេញ" និងដោយអង្គការសមាគមធាងត្នោតដែលមានចំណងជើងថា "ការស្ទង់មតិក្នុងរាជធានីភ្នំពេញ"។ ជាចុងក្រោយការស្រាវជ្រាវដែលមានថ្មីបំផុតនោះគឺការវាយតម្លៃដែលធ្វើឡើងដោយកម្មវិធីស្បៀងអាហារពិភពលោក ក្នុងឆ្នាំ ២០១៩ ស្តីពី "ភាពងាយរងគ្រោះក្នុងរាជធានីភ្នំពេញ"។

ការស្រាវជ្រាវរបស់សាលារាជធានីភ្នំពេញក្នុងឆ្នាំ ២០១២ បានបង្ហាញថា ៦០% នៃគ្រួសារកំពុងរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ។ ម្យ៉ាងទៀត វាក៏បង្ហាញឱ្យដឹងថាទីតាំងលំនៅឋានជាទូទៅខ្វះហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មចាំបាច់ ដូចជាប្រព័ន្ធលូបង្ហូរទឹកស្អុយត្រឹមត្រូវ (៣០%) និងការប្រមូលសំរាម (៤០%)[១៤]។ ខណៈដែលស្ថានភាពជីវភាពរបស់គ្រួសារក្រីក្រនៅក្នុងទីក្រុងមានសភាពត្រដាបត្រដួស និងលំបាក ការសិក្សាជាច្រើនក៏បានរកឃើញថាការបណ្តេញចេញដោយបង្ខំក៏កាន់តែកើនឡើង។ ការផ្លាស់ទីលំនៅថ្មីរបស់សហគមន៍ពីខណ្ឌខាងក្នុងទៅតំបន់ខាងក្រៅនៃទីក្រុងក៏ត្រូវបានអនុវត្ត ដោយមានការជួយជ្រោមជ្រែងតិចតួចពីរាជរដ្ឋាភិបាល។ របាយការណ៍នេះពិពណ៌នាអំពីស្ថានភាពរស់នៅរបស់សហគមន៍ដែលបានផ្លាស់ទៅទីតាំងលំនៅថ្មីដែលមានសភាពលំបាកកាន់តែខ្លាំងជាងទីតាំងចាស់របស់ពួកគេ[១៥]។

ក្នុងឆ្នាំ ២០០៩ ការស្រាវជ្រាវរបស់អង្គការសមាគមធាងត្នោតបានបង្ហាញឱ្យឃើញថា ស្ទើរតែ ៤០% នៃទីតាំងលំនៅឋានត្រូវបានរងការគំរាមកំហែងពីការបណ្តេញចេញ និងគំនាបសង្កត់ឱ្យផ្លាស់ទីលំនៅ[១៦]។ បញ្ហាមួយទៀតដែលបានលេចឡើងក្នុងការសិក្សាទាំងនេះ គឺថាទោះបីជាសហគមន៍ទាំងនេះកំពុងខិតខំការពារពីការបណ្តេញចេញក្តី ទំនុកចិត្តរបស់ពួកគេលើការគាំទ្រផ្នែកច្បាប់នៅតែមានកម្រិតទាប ដូចនេះគ្មានជម្រើសក្រៅពីបន្តតស៊ូដើម្បីការពារដីធ្លីរបស់ពួកគេ[១៧]។

ក្នុងឆ្នាំ ២០១៨ ធនាគារពិភពលោកបានឱ្យដឹងពីកំណើនថេរនៃផលិតផលក្នុងស្រុកសរុបដែលមានចំនួន ៦,៩% ក៏ប៉ុន្តែចំពោះសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញវិញ បញ្ហានៅតែមានទាក់ទងនឹងអនាម័យ ទីកន្លែងរស់នៅមានភាពកកកុញ និងកង្វះលំនៅឋានសមរម្យ និងមានសុវត្ថិភាព។ បញ្ហាផ្សេងទៀតរួមមានបញ្ហាបង្គន់អនាម័យ និងបញ្ហាសំរាមដោយសារកង្វះលទ្ធភាពក្នុងការទទួលបានសេវាប្រមូលសំរាម[១៨]។

នៅក្នុងការសិក្សាស្រាវជ្រាវថ្មីបំផុត "ភាពងាយរងគ្រោះនៅក្នុងរាជធានីភ្នំពេញ" ដែលបានធ្វើឡើងដោយកម្មវិធីស្បៀងអាហារពិភពលោក ក្នុងឆ្នាំ២០១៩ វឌ្ឍនភាពសំខាន់នៃលទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការទទួលបានសេវាអគ្គិសនី និងទឹកស្អាត ត្រូវបានសម្រេចបាន។ អ្នកចូលរួមផ្តល់បទសម្ភាសស្ទើរតែទាំងអស់មានអគ្គិសនី និង ទឹកស្អាតប្រើប្រាស់។ ប៉ុន្តែការជំពាក់បំណុលត្រូវបានរាយការណ៍ថាជាបញ្ហាចម្បងមួយរបស់គ្រួសារដែលរស់នៅក្នុងតំបន់ខណ្ឌខាងក្នុង (៣៩%) និងខណ្ឌខាងក្រៅ (១១%)។ កម្រិតបំណុលនេះនៅតែទាបជាងកម្រិតបំណុលនៅក្នុងតំបន់ជនបទ (៥៥%)[១៩]។

---

[១៤] យូនីសេហ្វ៖ រាជធានីភ្នំពេញ ពហុសូចនាករវាយតម្លៃភាពក្រីក្រនៅទីក្រុង ឆ្នាំ២០១២
[១៥] អង្គការសមាគមធាងត្នោត ការស្ទង់មតិក្នុងរាជធានីភ្នំពេញ ការសិក្សាអំពីទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងភ្នំពេញ ឆ្នាំ២០១៤
[១៦] ដូចខាងលើ
[១៧] ផ្អែកលើរបាយការណ៍អង្គការសមាគមធាងត្នោត យោងដោយ Cambodianess/Thmey Thmey៖ សហគមន៍ស្ថិតក្នុងឡោមព័ទ្ធ៖ ការប្រឆាំងនឹងការបណ្តេញចេញនៅក្នុងភ្នំពេញ ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០ https://cambodianess.com/article/community-under-siege-fighting-eviction-in-phnom-penh
[១៨] ខ្មែរថាមស៍៖ ប្រជាជនក្រីក្រនៅក្នុងទីក្រុងភ្នំពេញ ដោយ Hiezle Bual ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨
[១៩] កម្មវិធីស្បៀងអាហារពិភពលោក៖ ភាពងាយរងគ្រោះនៅក្នុងទីក្រុងភ្នំពេញ ខែឧសភា ឆ្នាំ២០១៩

# ៤. គោលបំណងនៃការសិក្សា

ការសិក្សានេះមានបំណងសម្រេចឱ្យបាននូវគោលបំណងដូចខាងក្រោម៖

- ផ្ដល់នូវទិដ្ឋភាពទូទៅអំពីស្ថានភាពបច្ចុប្បន្នរបស់សហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ ដោយផ្ដោតទៅលើសមាសភាគបីនៃភាពក្រីក្រ ពោលគឺ សុខភាព ការអប់រំ និងកម្រិតជីវភាព។
- ពិនិត្យមើល និងវាយតម្លៃលើវិធានការការពារផ្នែកសង្គមដែលមានសម្រាប់ប្រជាពលរដ្ឋក្រីក្រនៅក្នុងទីក្រុង។
- ពិនិត្យមើល និងវាយតម្លៃលើគម្រោងជំនួយទ្វេភាគី និងពហុភាគី ដែលផ្ដោតលើប្រជាពលរដ្ឋក្រីក្រនៅក្នុងទីក្រុង។
- កំណត់រកហានិភ័យថ្នាក់គោលនយោបាយនានាជាមួយតួអង្គពាក់ព័ន្ធទាំងអស់ទាក់ទងនឹងភាពក្រីក្រនៅក្នុងទីក្រុង។
- ឈ្វេងយល់ពីហេតុផលនៃចំណាកស្រុកពីតំបន់ជនបទមករាជធានីភ្នំពេញ។
- ផ្ដល់ជាអនុសាសន៍ទៅឱ្យភាគីពាក់ព័ន្ធអំពីគម្រោងដែលផ្ដោតលើសហគមន៍ក្រីក្រនៅក្នុងទីក្រុង ដោយផ្អែកតាមការរកឃើញនៃការស្រាវជ្រាវនេះ។
- ដើម្បីកំណត់រកចំណុចជាក់លាក់អំពីភាពប្រសើរឡើង ឬឱនភាពនៃស្ថានភាពរស់នៅរបស់សហគមន៍ក្រីក្រនៅក្នុងទីក្រុង។

# ៥. វិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្រត្រូវបានរៀបចំឡើងស្រដៀងគ្នានឹងសន្ទស្សន៍សកលនៃភាពក្រីក្រពហុសមាសភាគ។ ដោយផ្អែកលើបរិបទនៃតំបន់គោលដៅ ក្រុមទីប្រឹក្សាបានសម្រេចជ្រើសយកវិធីសាស្ត្រចំនួន ៣ សម្រាប់ប្រើប្រាស់ ដែលរួមមានការសិក្សាឯកសារពាក់ព័ន្ធ ការស្ទង់មតិតាមគ្រួសារ និងការសម្ភាសពាក់កណ្តាលរៀបរយ។

## ក. ការសិក្សាឯកសារពាក់ព័ន្ធ

ការសិក្សាលើឯកសារពាក់ព័ន្ធត្រូវបានប្រើប្រាស់ជាផ្នែកដ៏សំខាន់មួយនៅក្នុងដំណើរការនៃការស្រាវជ្រាវទាំងមូលនេះ។ ក្នុងបរិបទនៃការសិក្សានេះ ការសិក្សាឯកសារពាក់ព័ន្ធមានមុខងារជាច្រើនដូចខាងក្រោម៖

- ជួយកំណត់ឱ្យច្បាស់អំពីបញ្ហាដែលត្រូវធ្វើការសិក្សា។
- ជួយឱ្យការរៀបចំបង្កើតវិធីសាស្ត្រ និងកម្រងសំណួរមានមូលដ្ឋានត្រឹមត្រូវ និងសមរម្យ។
- ធានាថាលទ្ធផលរកឃើញសំខាន់ៗស្របទៅនឹងបរិបទបង្ហាញតថភាពពិត និងទទួលយកបានដោយ។
- ភាគីពាក់ព័ន្ធសំខាន់ៗ។

ដើម្បីឱ្យមានការយល់ដឹងស៊ីជម្រៅ អំពីលក្ខណៈនៃគម្រោងនេះ ក្រុមអ្នកស្រាវជ្រាវបានពិនិត្យមើលលើឯកសារដូចជា៖

- របាយការណ៍ផ្សេងៗជាច្រើនទាក់ទងនឹងសហគមន៍ក្រីក្រនៅក្នុងទីក្រុង។
- សន្ទស្សន៍សកលស្តីពីភាពក្រីក្រពហុសមាសភាគ
- របាយការណ៍ស្ថិតិបានមកពីប្រភពផ្សេងៗពាក់ព័ន្ធនឹងសាវតារគម្រោង។
- របាយការណ៍ និងគោលនយោបាយពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា។

## ខ. ការស្ទង់មតិតាមគ្រួសារ

គ្រួសារចំនួន ៩៥៨ ត្រូវបានស្ទង់មតិនៅក្នុងការស្រាវជ្រាវនេះ។ ចំនួននេះប្រមាណជា ១០ ទៅ ១៥% នៃប្រជាពលរដ្ឋសរុបនៅក្នុងតំបន់ដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ ហើយទំហំសំណាកនេះគឺមានលក្ខណៈគ្រប់គ្រាន់ដើម្បីយកទៅធ្វើការសិក្សា។

កម្រងសំណួរដែលមានលក្ខណៈពាក់កណ្តាលរៀបរយត្រូវបានរៀបចំឡើងដែលភាគច្រើនជាសំណួរបិទ។ សំណួរទាំងនេះមានគោលបំណងវាស់វែងអំពីស្ថានភាពផ្នែកនយោបាយ និងសង្គម-សេដ្ឋកិច្ចរបស់សហគមន៍ និងគ្រួសារដូចខាងក្រោម៖

- សាវតាររបស់គ្រួសារ
- ចំណូល និងស្ថានភាពផ្នែកសង្គម-សេដ្ឋកិច្ចបច្ចុប្បន្នរបស់គ្រួសារ
- បំណុល និងកម្ចីរបស់គ្រួសារ
- ការអប់រំរបស់កុមារ
- ស្ថានភាពរស់នៅ
- ការថែទាំសុខភាព
- ចំណាកស្រុក
- ការជួយជ្រោមជ្រែងជីវភាពប្រកបដោយចីរភាព
- កម្មវិធីសន្តិសុខសង្គម
- ការទទួលបានព័ត៌មាន

កម្រងសំណួរទាំងនេះត្រូវបានសាកល្បងសួរ និងកែសម្រួលដើម្បីធានាថាអាចប្រើប្រាស់បាន មុនពេលយកទៅប្រើជាមួយនឹងអ្នកផ្តល់បទសម្ភាសដែលត្រូវបានជ្រើសរើសក្នុងការសិក្សានេះ។

## គ. ការជ្រើសយកសំណាក

អ្នកចូលរួមផ្តល់បទ សម្ភាសចំនួន ៩៥៨ នាក់ត្រូវបានជ្រើសរើសសម្រាប់ធ្វើការសម្ភាស។ បុគ្គលិកកម្មវិធីរបស់អង្គការសមាគមធាងត្នោតបានផ្តល់ជំនួយដើម្បីស្វែងរក និង

ទំនាក់ទំនងជាមួយសហគមន៍ និងអ្នកចូលរួមផ្ដល់បទសម្ភាស។ ការជ្រើសយកសំណាក គឺជាដំណើរការនៃការជ្រើសរើសមនុស្សមួយចំនួនចេញពីក្រុមប្រជាពលរដ្ឋធំមួយសម្រាប់ធ្វើជាមូលដ្ឋានសន្មត ឬព្យាករណ៍អំពីទិដ្ឋភាពទូទៅនៃព័ត៌មាន ស្ថានភាព និងលទ្ធផលដែលមិនទាន់ត្រូវបានគេឈ្វេងយល់អំពីក្រុមធំមួយនោះ[២០]។

បញ្ហាដូចជាជំងឺកូវីដ-១៩ និងទឹកជំនន់នៅក្នុងសហគមន៍បានធ្វើឱ្យក្រុមអ្នកស្រាវជ្រាវសម្រេចប្រើប្រាស់វិធីសាស្ត្រជ្រើសរើសសំណាកតគ្នាពីម្នាក់ទៅម្នាក់ទៀត។ វិធីសាស្ត្រនេះទាមទារឱ្យសមាជិកសហគមន៍ចង្អុលប្រាប់ពី សមាជិកផ្សេងទៀតដែលអាចនឹងចាប់អារម្មណ៍ចូលរួមការស្ទង់មតិ ហើយបានប្រើប្រាស់ Transact Walk សម្រាប់ការពិភាក្សាជាមួយនឹងអ្នកដឹកនាំសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។

## ឃ. ការសម្ភាសបែបពាក់កណ្ដាលរៀបរយ

### ១. ការសម្ភាសជាមួយបុគ្គល

ផ្អែកតាមវិសាលភាពនៃការសិក្សាស្រាវជ្រាវ ការសម្ភាសបែបពាក់កណ្ដាលរៀបរយត្រូវបានអនុវត្តជាមួយនឹងអ្នកដឹកនាំសហគមន៍ ហើយការពិភាក្សាជាក្រុមមួយចំនួនក៏ត្រូវបានរៀបចំឡើង។ ប៉ុន្តែដោយសារការផ្ទុះ និងរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងរាជធានីភ្នំពេញ ការជួបជុំជាក្រុមត្រូវបានហាមឃាត់ តែការសម្ភាសជាមួយបុគ្គលនៅតែអាចធ្វើឡើងបានតាមរយៈទូរស័ព្ទ។

### ២. វិធីសាស្ត្រនៃការវិភាគទិន្នន័យ

ទិន្នន័យទាំងអស់ដែលប្រមូលបានតាមគ្រួសារត្រូវបានបញ្ចូលទៅក្នុងកុំព្យូទ័រតាមរយៈ Excel Spreadsheet។ ការវិភាគត្រូវបានធ្វើឡើងតាមវិធីសាស្ត្រត្រីកោណ ដែលការរកឃើញទាំងអស់ត្រូវមានការបញ្ជាក់ពីប្រភពយ៉ាងតិចចំនួន បី។

[២០] Ranjit Kumar, វិធីសាស្ត្រស្រាវជ្រាវ ការណែនាំជាជំហានកម្រិតដំបូង

# ៦. វិសាលភាព និងដែនកំណត់

ខណៈពេលចុះស្ទង់មតិនៅតាមទីតាំងផ្ទាល់ ក្រុមអ្នកស្រាវជ្រាវបានជួបប្រទះនឹងបញ្ហាមួយចំនួនដែលអាចបង្កផលប៉ះពាល់ដល់គុណភាពព័ត៌មានដែលប្រមូលបាន។ ក្រុមអ្នកស្រាវជ្រាវខ្លះមិនត្រូវបានអនុញ្ញាតឱ្យធ្វើការសម្ភាសជាមួយអ្នកដឹកនាំសហគមន៍។ ក្នុងករណីនេះ សមាជិកក្រុមបានសម្រេចជ្រើសយកសហគមន៍ថ្មីជំនួស។ លើសពីនេះទៀត ដោយសារការវាយតម្លៃត្រូវបានធ្វើឡើងចំពេលផ្ទុះ និងរីករាលដាលនៃជំងឺកូវីដ-១៩នៅក្នុងរាជធានីភ្នំពេញ ការណាត់ជួបសម្ភាសជាច្រើនត្រូវបានលុបចោល។ ការលុបចោលទាំងនេះក៏រួមមានការពិភាក្សាជាក្រុមផងដែរ។

ការផ្លាស់ប្តូរវិធីសាស្ត្រនៃការសិក្សា ពីការពិភាក្សាជាក្រុមមកការសម្ភាសជាបុគ្គលនេះ អាចនាំឱ្យខ្វះការចូលរួមពេញលេញពីសមាជិកសហគមន៍ផ្សេងទៀត ហើយជាការពិតណាស់ មតិយោបល់ និងធាតុចូលរបស់ពួកគេអាចត្រូវបានមើលរំលង។

ទឹកជំនន់ក៏ជាបញ្ហាប្រឈមមួយផ្សេងទៀត ដែលធ្វើឱ្យក្រុមអ្នកស្រាវជ្រាវបានសម្រេចរំលងសមាជិកគ្រួសារមួយចំនួន ព្រោះតែមិនងាយស្រួលចូលទៅដល់ទីតាំង។ ដូចនេះ សមាជិកសហគមន៍ដែលរងផលប៉ះពាល់ខ្លាំងមួយចំនួនអាចមិនត្រូវបានតំណាងនៅក្នុងការរកឃើញទាំងនេះ។

ចុងក្រោយ បញ្ហាប្រឈមសំខាន់មួយទៀត គឺចំនួននៃការសម្ភាស ដែលមិនមានភាពសមាមាត្រគ្នានៅក្នុងប្រាំសហគមន៍ (សូមមើលតារាងទី ១ ខាងក្រោម)។ ចំនួនមិនសមាមាត្រគ្នានេះអាចធ្វើឱ្យការរកឃើញមួយចំនួនលំអៀងទៅលើទំនោរនៅក្នុងសហគមន៍ទាំងនេះដែលអាចខុសពី ឬមិនមានវត្តមាននៅក្នុងសហគមន៍ផ្សេងទៀត។ ឧទាហរណ៍មួយនោះគឺប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លី។ ព្រែកតាគង់ ១ គឺជាសហគម៍ក្រីក្រមួយនៅក្នុងទីក្រុង ដែលជាង ៥% នៃអ្នកចូលរួមផ្តល់បទសម្ភាសមកពីសហគមន៍នេះ ហើយភាគច្រើនមានប័ណ្ណកាន់កាប់ដីធ្លី។ នេះអាចធ្វើឱ្យទិន្នន័យលំអៀងនិងបង្ហាញថាគ្រួសារក្រីក្រភាគច្រើននៅក្នុងរាជធានីភ្នំពេញមានប័ណ្ណកាន់កាប់ដីធ្លី។

# ៧. តំបន់គោលដៅសម្រាប់ការសិក្សានេះ

ការសិក្សាវាយតម្លៃនេះត្រូវបានធ្វើឡើងក្នុងសហគមន៍ក្រីក្រចំនួន ៤២ ទីតាំង ក្នុងខណ្ឌទាំងអស់ នៅក្នុងរាជធានីភ្នំពេញ (សូមមើលតារាងទី ១)។

តារាងទី ១៖ បញ្ជីឈ្មោះសហគមន៍ដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ

| ល.រ | បរិយាយ | ចំនួន | % | ល.រ | បរិយាយ | ចំនួន | % |
|---|---|---|---|---|---|---|---|
| ១ | ច្រាំងចំរេះ | ១១៤ | ១១,៩ | ២២ | បឹងត្របែក ភូមិ ៤ | ១៦ | ១,៦៧ |
| ២ | ស្ទឹងជ្រៅ | ៩៧ | ១០,១៣ | ២៣ | សាមគ្គី ៣.១ | ១៥ | ១,៥៧ |
| ៣ | ស្ទឹងមានជ័យ | ៥៦ | ៥,៨៥ | ២៤ | បុរីសន្តិភាព | ១៥ | ១,៥៧ |
| ៤ | ព្រែកតាគង់ ១ | ៥៥ | ៥,៧៤ | ២៥ | ឫស្សីស្រស់ | ១៤ | ១,៤៦ |
| ៥ | សែនរីករាយ | ៤៥ | ៤,៧ | ២៦ | សាមគ្គីរុងរឿង | ១៣ | ១,៣៦ |
| ៦ | ស្ទឹងកំបុត | ៤១ | ៤,២៨ | ២៧ | រួមមិត្ត | ១៣ | ១,៣៦ |
| ៧ | ភូមិ ២៣ | ៣៩ | ៤,០៧ | ២៨ | បឹងឈូក អេ | ១១ | ១,១៥ |
| ៨ | ត្រពាំងរាំង | ៣០ | ៣,១៣ | ២៩ | រលួសជើងឯក | ១១ | ១,១៥ |
| ៩ | ចំរើន | ២៨ | ២,៩២ | ៣០ | បុរីមិត្តភាព | ១១ | ១,១៥ |
| ១០ | ចំរើនអភិវឌ្ឍន៍ | ២៥ | ២,៦១ | ៣១ | កោះនរា | ១០ | ១,០៤ |
| ១១ | ស្មសាន | ២៤ | ២,៥១ | ៣២ | ព្រែកតាគង់ ៦០ម៉ែត្រ | ៩ | ០,៩៤ |
| ១២ | សំរោងត្បូង | ២៣ | ២,៤ | ៣៣ | ស្ត្រីឃ្លាំងសាំង | ៩ | ០,៩៤ |
| ១៣ | ជើងឯក ក្រុម ៣ | ២៣ | ២,៤ | ៣៤ | រីកចំរើន | ៨ | ០,៨៤ |
| ១៤ | ទួលពង្រសែនជ័យ | ២២ | ២,៣ | ៣៥ | រស្មីជ្រោយចង្វារ | ៨ | ០,៨៤ |
| ១៥ | ទួលស្វាយព្រៃមួយ | ២១ | ២,១៩ | ៣៦ | ជើងឯកក្រុម ៤ | ៧ | ០,៧៣ |
| ១៦ | ផ្លូវរថភ្លើង | ២០ | ២,០៩ | ៣៧ | បឹងឈូក | ៧ | ០,៧៣ |
| ១៧ | ដើមស្រល់ | ២០ | ២,០៩ | ៣៨ | បឹកឈូកមានជ័យ | ៦ | ០,៦៣ |
| ១៨ | សហគមន៍ ១០៤ | ១៩ | ១,៩៨ | ៣៩ | អភិវឌ្ឍន៍ថ្មី | ៦ | ០,៦៣ |
| ១៩ | សហគមន៍ ១០៥ | ១៨ | ១,៨៨ | ៤០ | បុរីកីឡា | ៦ | ០,៦៣ |
| ២០ | សហគមន៍ ៩២ | ១៨ | ១,៨៨ | ៤១ | ស្រែអំបិលថ្មី | ៤ | ០,៤២ |
| ២១ | ទួលសង្កែ អេ | ១៧ | ១,៧៧ | ៤២ | ព្រែកតាគង់ ៣ | ៤ | ០,៤២ |
| សរុប | | | | | | ៩៥៨ | ១០០ |



# ៨. ការរកឃើញសំខាន់ៗ

ផ្នែកនេះ ផ្តល់នូវព័ត៌មានលម្អិតអំពីការរកឃើញនៃការសិក្សានេះ។ ការរកឃើញត្រូវបានបែងចែកជាផ្នែកតូចៗដូចខាងក្រោម៖

ក. សាវតាររបស់អ្នកចូលរួមផ្តល់បទសម្ភាស
ខ. ស្ថានភាពសង្គម-សេដ្ឋកិច្ចគ្រួសារ
គ. លំនៅឋាន
ឃ. ឯកសារគ្រួសារ
ង. ការទទួលបានសេវាថែទាំសុខភាព
ច. ការអប់រំរបស់កុមារ
ឆ. ភាពងាយរងគ្រោះនៅក្នុងគ្រួសារ
ជ. អនាម័យ និងអនាម័យខ្លួនប្រាណ
ឈ. ទ្រព្យសម្បត្តិរបស់ក្រុមគ្រួសារ
ញ. លទ្ធភាពទទួលបានអគ្គិសនីរបស់សហគមន៍
ដ. ថាមពលសម្រាប់ចម្អិនអាហារ

## ក. សាវតាររបស់អ្នកចូលរួមផ្តល់បទសម្ភាស

ដូចបានបង្ហាញនៅក្នុងតារាងទី ១ ខាងលើ មានអ្នកចូលរួមផ្តល់បទសម្ភាសចំនួន ៩៥៨ នាក់ បានចូលរួមក្នុងការសិក្សានេះ។ ក្នុងចំណោមនោះ ៧៧% ជាស្ត្រី និង ២៣% ជាបុរស (សូមមើលក្រាហ្វិចទី ១)។ បើយោងតាមអ្នកដឹកនាំសហគមន៍ ភាគច្រើនជាស្ត្រីដែលមានពេលចូលរួមផ្តល់បទសម្ភាស ព្រោះបុរសនៅក្នុងសហគមន៍ភាគច្រើនជាប់រវល់ធ្វើការងារនៅក្រៅសហគមន៍នៅអំឡុងពេលនៃការសម្ភាស។ ការរកឃើញមួយនេះបានឆ្លុះបញ្ចាំងពីទំនាក់ទំនងយេនឌ័រក្នុងសហគមន៍ក្រីក្រនៅក្នុងទីក្រុង ដែលបុរសចេញទៅធ្វើការក្រៅផ្ទះនៅពេលថ្ងៃ ឬបានធ្វើចំណាកស្រុកពីសហគមន៍ដើម្បីធ្វើការងារ។ អ្នកដឹកនាំសហគមន៍ក៏បានប្រាប់ក្រុមអ្នកស្រាវជ្រាវឱ្យដឹងថាការរកឃើញអាចមកពីកម្មករ (ភាគច្រើនជាបុរស) មិនត្រូវបានអនុញ្ញាតឱ្យធ្វើដំណើរពីកន្លែងការងារទៅផ្ទះសម្បែងដោយសេរីនោះទេ ព្រោះតែការវិធានការជំងឺកូវីដ-១៩។

ក្រាហ្វិចទី១៖ ភេទរបស់អ្នកចូលរួមផ្តល់បទសម្ភាស




ប្រមាណ ៣៣% នៃអ្នកចូលរួមផ្តល់បទសម្ភាសមានអាយុចន្លោះពី ១៨ ទៅ ៣៩ឆ្នាំ ហើយ ៤៧% មានអាយុចន្លោះពី ៤០ ទៅ ៦០ឆ្នាំ។ ប្រមាណ ២០% នៃអ្នកចូលរួមផ្តល់បទសម្ភាសមានអាយុលើសពី ៦០ឆ្នាំ (សូមមើលក្រាហ្វិចទី២)។ អ្នកផ្តល់បទសម្ភាសនៅក្នុងការសិក្សានេះភាគច្រើន (៨០%) មានអាយុដែលអាចនៅធ្វើការងារបាន (ឬមិនទាន់ចូលនិវត្តន៍)។

ក្រាហ្វិចទី២៖ អាយុរបស់អ្នកចូលរួមផ្តល់បទសម្ភាស



គួរឱ្យចាប់អារម្មណ៍ផងដែរ ដូចមានបង្ហាញនៅក្នុងក្រាហ្វិចខាងក្រោម ជាង ២០% នៃអ្នកចូលរួមផ្តល់បទសម្ភាសបានអះអាងថាជាបុរសពោះម៉ាយ (សូមមើលក្រាហ្វិចទី៣)។ តួលេខនេះអាចជាបញ្ហាដល់កម្រិតចំណូលរបស់គ្រួសារក្រីក្រនៅក្នុងទីក្រុងទាំងអស់ ដូចមានពិភាក្សាខាងក្រោមនេះ។ លើសពីនេះទៀត គួរបញ្ជាក់ផងដែរថា សមាជិកគ្រួសារក្នុងការសិក្សានេះជាមធ្យមមានចំនួន ៥នាក់ ក្នុងមួយគ្រួសារ។ តួលេខនេះស្របនឹងទិន្នន័យរកឃើញនៅក្នុង "ជំរឿនជាតិឆ្នាំ ២០១៩" ដែលបោះពុម្ពដោយក្រសួងផែនការ។

ក្រាហ្វិចទី៣៖ ស្ថានភាពគ្រួសារ




កម្រិតនៃការអប់រំរបស់អ្នកចូលរួមផ្តល់បទសម្ភាសបង្ហាញថាជាង ២១% មិនទទួលបានការអប់រំផ្លូវការ។ មួយភាគបួន (២៥%) ទៀតបានឆ្លើយថា ពួកគេបានបញ្ចប់បឋមសិក្សាកម្រិតទាប ខណៈដែល ២២% បានរៀនដល់បឋមសិក្សាកម្រិតខ្ពស់។ ក្នុងនោះផងដែរ ២១% បានបញ្ចប់អនុវិទ្យាល័យ និងមានតែ ៧% ប៉ុណ្ណោះដែលបានរៀនដល់ថ្នាក់វិទ្យាល័យ (សូមមើលតារាងទី ៥ ខាងក្រោម)។

កម្រិតនៃការអប់រំមានសារៈសំខាន់នៅពេលពិចារណាពីផលប៉ះពាល់នៃការបណ្តេញចេញ ឬការផ្លាស់ទីលំនៅថ្មី ឬអាចមានផលប៉ះពាល់អវិជ្ជមានលើការងារ។ អ្នកដែលមានកម្រិតនៃការអប់រំទាបមានជម្រើសតិចក្នុងការស្វែងរកការងារថ្មីធ្វើ។

តារាងទី២៖ កម្រិតនៃការអប់រំរបស់អ្នកចូលរួមផ្តល់បទសម្ភាស

| ល.រ | បរិយាយ | ចំនួន | % |
|---|---|---|---|
| ១ | គ្មានការអប់រំ | ២០៨ | ២១,៧៦% |
| ២ | ថ្នាក់ទី ៣ | ១១២ | ១១,៧២% |
| ៣ | ថ្នាក់ទី ៥ | ៩៩ | ១០,៣៦% |
| ៤ | ថ្នាក់ទី ៧ | ៨៦ | ៩% |
| ៥ | ថ្នាក់ទី ២ | ៨១ | ៨,៤៧% |
| ៦ | ថ្នាក់ទី ៩ | ៧៦ | ៧,៩៥% |
| ៧ | ថ្នាក់ទី ៦ | ៥៤ | ៥,៦៥% |
| ៨ | ថ្នាក់ទី ៤ | ៥៣ | ៥,៥៤% |
| ៩ | ថ្នាក់ទី ៨ | ៤៩ | ៥,១៣% |
| ១០ | ថ្នាក់ទី ១ | ៤៦ | ៤,៨១% |
| ១១ | ថ្នាក់ទី ១២ | ៤៤ | ៤,៦០% |
| ១២ | ថ្នាក់ទី ១០ | ២២ | ២,៣០% |
| ១៣ | បញ្ចប់សាកលវិទ្យាល័យ | ១០ | ១,០៥% |
| ១៤ | ថ្នាក់ទី ១១ | ៧ | ០,៧៣% |
| ១៥ | ក្រោយឧត្តមសិក្សា | ៧ | ០,៥២% |
| ១៦ | សាកលវិទ្យាល័យឆ្នាំទី ៣ | ៣ | ០,៣១% |
| ១៧ | សាកលវិទ្យាល័យឆ្នាំទី ១ | ១ | ០,១០% |
| សរុប | | ៩៥៨ | ១០០% |

ជាង ៦៩% នៃអ្នកចូលរួមផ្តល់បទសម្ភាសបានរាយការណ៍ថារស់នៅក្នុងសហគមន៍របស់ពួកគេបច្ចុប្បន្ននេះបានជាង ១០ឆ្នាំមកហើយ។ ប្រមាណជាង ១៣% នៃឆ្លើយតបថាបានកើតនៅក្នុងសហគមន៍ និងជាង ៧% រស់នៅក្នុងសហគមន៍បានក្រោម ១០ ឆ្នាំ។ មានជាង ៣% នៃអ្នកចូលរួមផ្តល់បទសម្ភាស ទើបតែផ្លាស់មករស់នៅក្នុងសហគមន៍ក្នុងអំឡុងពេល ៤ ទៅ ៥ ឆ្នាំកន្លងមកនេះ (សូមមើលក្រាហ្វិចទី៤)។ តួលេខនេះស្រដៀងនឹងការសង្កេតមើលឃើញរបស់អ្នកដឹកនាំសហគមន៍មួយចំនួនដែលបានផ្តល់ការសម្ភាស។ អ្នកដឹកនាំសហគមន៍ទាំងនោះបានរៀបរាប់ប្រាប់ថាប្រជាពលរដ្ឋក្នុងសហគមន៍របស់ពួកគេជារួមមិនសូវផ្លាស់ប្តូរទីលំនៅនោះ

ទេ បើធៀបទៅនឹង ១០ ឆ្នាំមុន។ ផ្ទុយទៅវិញ ជាង៧% នៃអ្នករស់នៅក្នុងសហគមន៍ទើបតែមករស់នៅក្នុងសហគមន៍ (ក្នុងរយៈពេលតិចជាង ៤ឆ្នាំកន្លងមកនេះ) ដែលជាភស្តុតាងបង្ហាញថាប្រជាពលរដ្ឋបន្តផ្លាស់ទីមករស់នៅតំបន់ក្រីក្រនៅក្នុងទីក្រុង។

ក្រាហ្វិចទី៤៖ រយៈពេលនៃការរស់នៅក្នុងសហគមន៍




អ្នកចូលរួមក្នុងការសិក្សានេះស្ទើរតែទាំងអស់ ៩១% គឺមេគ្រួសារជាស្ត្រី (ឬមួយក្នុងចំណោមមេគ្រួសារ) (សូមមើលក្រាហ្វិចទី ៥ ខាងក្រោម)។ តួលេខនេះត្រូវបានគេរំពឹកទុកជាមុន និងបញ្ជាក់ម្តងទៀតថាស្ត្រីជារឿយៗគឺជាមេគ្រួសារ។ ម៉្យាងវិញទៀត អ្នកចូលរួមផ្តល់បទសម្ភាសតែងតែអះអាងថាអាចឆ្លើយនឹងសំណួរទាំងអស់ដោយមានភាពជឿជាក់បានព្រោះតែតួនាទីរបស់ពួកគេនៅក្នុងគ្រួសារ។

ក្រាហ្វិចទី៥៖ ទំនាក់ទំនងក្នុងក្រុមគ្រួសារ





## ខ. ស្ថានភាពសង្គម-សេដ្ឋកិច្ចក្នុងគ្រួសារ

នៅក្នុងការសម្ភាស អ្នកចូលរួមផ្តល់បទសម្ភាសត្រូវបានស្នើឱ្យជ្រើសយកប្រភពចំណូលចម្បង ៣ ដែលគ្រួសាររបស់ពួកគេមាន ក្នុងចំណោមប្រភពចំណូលទាំងអស់ក្នុងបញ្ជី (សូមមើលតារាងទី ៣)។ ការរកឃើញបង្ហាញថា ២១%នៃចំណូលចម្បងបានមកពី "តូបលក់ដូរ" ដូចជាតូបលក់ចំណីអាហារ ឬទឹកភេសជ្ជ នៅក្នុងភូមិ ១៣% បានមកពីប្រភពមុខរបរផ្សេងៗ ខណៈដែល ១៣% នៃចំណូលចម្បងបានមកពីការងារជាកម្មកររោងចក្រ។ ស្រដៀងគ្នាផងដែរ ១៣% បានចំណូលមកពីការងារជាកម្មករសំណង់ ១១% បានចំណូលមកពីធ្វើការក្នុងក្រុមហ៊ុន ហើយ ៩.១៩% បានចំណូលពីការរត់តាក់ស៊ី ឬម៉ូតូឌុប និងរ៉ឺម៉កទេសចរណ៍។ ចំណូលបានពីការធ្វើដំណាំចម្ការ ការងាររដ្ឋ ការប្រមូលសំណល់កែច្នៃ និងការងារសិប្បកម្ម មានចំនួនតិចតួចបំផុត ប៉ុន្តែក៏ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីការងារផ្តល់ចំណូលផងដែរ។

គួរបញ្ជាក់ផងដែរថាសហគមន៍ក្រីក្រមួយចំនួននៅក្នុងទីក្រុងដែលត្រូវបានជ្រើសរើសក្នុងការស្រាវជ្រាវនេះ ដូចជាព្រែកតាគង់ ១ មានភាគរយនៃកសិករខ្ពស់ជាងមធ្យម ដោយសារទីតាំងរបស់ពួកគេនៅក្បែរដីដំណាំនៅប៉ែកខាងត្បូងនៃរាជធានីភ្នំពេញ។ នេះអាចមានន័យថាចំណូលបានពីការធ្វើកសិកម្មអាចមិនមានភាពសមាមាត្រនៅក្នុងការសិក្សានេះ ប៉ុន្តែវាមានប្រយោជន៍ក្នុងកត់សម្គាល់ថាសហគមន៍ជាច្រើនដែលរស់នៅលើ ឬក្បែរបឹង ឬដីសើម ចិញ្ចឹមត្រី និងធ្វើវារីវប្បកម្មជាប្រចាំក្នុងតំបន់ទាំងនោះ។

តារាងទី ៣៖ ប្រភពប្រាក់ចំណូលរបស់អ្នកចូលរួមផ្តល់បទសម្ភាស

| ល.រ | បរិយាយ | ចំ.មុខរបរ | % |
|---|---|---|---|
| ១ | លក់ដូរតាមតូបនៅក្នុងភូមិ | ២៨០ | ២១.០៨ |
| ២ | ប្រភេទមុខរបរផ្សេងៗ* | ១៨៥ | ១៣.៩៣ |
| ៣ | កម្មកររោងចក្រ | ១៨១ | ១៣.៦៣ |
| ៤ | កម្មករសំណង់ | ១៨០ | ១៣.៥៥ |
| ៥ | បុគ្គលិកក្រុមហ៊ុន | ១៤៨ | ១១.១៤ |
| ៦ | រត់ឡានតាក់ស៊ី ឬម៉ូតូឌុប | ១២២ | ៩.១៩ |
| ៧ | កសិករ | ៨០ | ៦.០២ |
| ៨ | បុគ្គលិករដ្ឋ/មន្ត្រីរាជការ | ៥៧ | ៤.២៩ |
| ៩ | អ្នកប្រមូលសំណល់កែច្នៃឡើងវិញ | ៣៧ | ២.៧៩ |
| ១០ | សិប្បកម្ម | ២១ | ១.៥៨ |
| ១១ | សេវាកម្មកំសាន្ត | ១៦ | ១.២០ |
| ១២ | បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល | ១៤ | ១.០៥ |
| ១៣ | សេវាកម្មបោកអ៊ុត | ៧ | ០.៥៣ |
| សរុប | | ១៣២៨ | ១០០% |

*កម្មករលីសែង កាត់ដេរនិងបើកបរ កូនផ្តល់ឱ្យ គ្មានការងារទេចាស់ជរាហើយ ចុងភៅ ចាំដីអោយគេ ជាងឡាន ធ្វើនំលក់នេសាទត្រី រត់តុ និងបេះត្រកួន រត់រម៉កម៉ូតូ លក់ online លក់ពងទា ពងមាន់លក់លៀសហាល លាងចានឲ្យគេ ស៊ីឈ្នួលគេ អនាម័យ។

ក្រាហ្វិចទី ៦ ផ្តល់នូវការយល់ដឹងពីអ្នករកចំណូលក្នុងគ្រួសារនីមួយៗមុនពេលជំងឺកូវីដ-១៩។ ការរកឃើញសំខាន់មួយគឺ ប្រមាណ ៤៤% នៃចំនួនអ្នកចូលរួមផ្តល់បទសម្ភាសសរុបមានអ្នករកចំណូលចំនួន ២នាក់ យ៉ាងតិចនៅក្នុងគ្រួសាររបស់ពួកគេ។ តារាងក៏បង្ហាញថាយ៉ាងហោចណាស់ មាន ៣% ផ្សេងទៀតមានអ្នករកប្រាក់ចំណូលពីចន្លោះ ៥ ទៅ ១០ នាក់នៅក្នុងគ្រួសារ។ ផ្អែកតាមការសម្ភាសជាមួយអ្នកដឹកនាំសហគមន៍ គ្រួសារទាំងនេះមិនមែនជាប្រភេទគ្រួសារសាមញ្ញនោះទេ តែជាគ្រួសារដែលមានសមាជិកជាពលករជាទូទៅជាជនចំណាកស្រុកវ័យក្មេង ព្រមទាំងរស់នៅជុំគ្នាក្នុងផ្ទះតែមួយដើម្បីសន្សំសំចៃដូចជាថ្លៃជួលផ្ទះ។

ក្រាហ្វិចទី៦៖ អ្នករកចំណូលនៅក្នុងគ្រួសារមុនជំងឺកូវីដ-១៩




ដូចដែលក្រាហ្វិចទី ៧ បានបង្ហាញ ជំងឺកូវីដ-១៩បានប៉ះពាល់ដល់ការរក្សាបាននូវការងារ។ លើសពី ៣២% នៃអ្នកចូលរួមផ្តល់បទសម្ភាសថាបានបាត់បង់ការងារក្នុងអំឡុងពេលផ្ទុះ និងរីករាលដាលនៃជំងឺកូវីដ-១៩ ខណៈដែល ៦៨% ផ្សេងទៀតអះអាងថាមិនធ្លាប់បាត់បង់ការងារ (សូមមើលក្រាហ្វិចទី ៧ ខាងក្រោម)។ តួលេខនេះបញ្ជាក់ថាជាងមួយភាគបី នៃគ្រួសារក្រីក្រនៅក្នុងទីក្រុងបានបាត់បង់ប្រភពចំណូលចម្បងមួយក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩។

ក្រាហ្វិចទី៧៖ ភាគរយនៃអ្នកចូលរួមផ្តល់បទសម្ភាសអំពី ការបាត់បង់ការងារបន្ទាប់ពីមានជំងឺកូវីដ




ក្នុងចំណោមក្រុមគ្រួសារដែលបានបាត់បង់ការងារ ជាងពាក់កណ្តាល (៥៦%) មានសមាជិកគ្រួសារម្នាក់បាត់បង់ការងារ។ ក្បែរមួយភាគបី (៣២%) នៃគ្រួសារ មានសមាជិក ២នាក់បាត់បង់ការងារ និង ៨% បានប្រាប់ថាមានសមាជិកគ្រួសារ ៣ នាក់បានបាត់បង់ការងាររបស់ពួកគេ។

ក្រាហ្វិចទី៨៖ ចំនួនសមាជិកគ្រួសារដែលបានបាត់បង់ការងារ អំឡុងពេលជំងឺកូវីដ-១៩




តារាងទី ៤ បង្ហាញពីតម្លៃសេដ្ឋកិច្ចនៃការបាត់បង់ការងារដែលបានពិភាក្សានៅក្នុងតារាងទី ១១។ ៣១% នៃអ្នកចូលរួមផ្តល់បទសម្ភាស បានបាត់បង់ចំណូលបានចន្លោះពី ១ ០០០ ០០០ ទៅ ២ ០០០ ០០០ រៀល (ឬចន្លោះពី ២៥០ ដុល្លារអាមេរិក ទៅ ៥០០ ដុល្លារអាមេរិក) ក្នុងមួយខែដោយសារបាត់បង់ការងារព្រោះតែជំងឺកូវីដ-១៩។ ជិត ៣១ % បានរាយការណ៍ថា បាត់បង់ប្រាក់ចំណូលលើសពី ២ ០០០ ០០០ រៀល (លើសពី ៥០០ ដុល្លារអាមេរិក) ក្នុងមួយខែ។

តារាងទី ៤៖ ការបាត់បង់ចំណូលពីការងារក្នុងអំឡុងពេលជំងឺកូវីដ-១៩

| ល.រ | បរិយាយ | ចំនួន | % |
|---|---|---|---|
| ១ | ចន្លោះពី ១ ០០០ ០០០ ទៅ ២ ០០០ ០០០ រៀល | ៣០១ | ៣១.៤២ |
| ២ | លើស ២ ០០០ ០០០ រៀល | ២៩៣ | ៣០.៥៨ |
| ៣ | ចន្លោះពី ៨០០ ០០០ ទៅ ១ ០០០ ០០០ រៀល | ១១៨ | ១២.៣២ |
| ៤ | ចន្លោះពី ៧០០ ០០០ ទៅ ៨០០ ០០០ រៀល | ៧៤ | ៧.៧២ |
| ៥ | ចន្លោះពី ៦០០ ០០០ ទៅ ៧០០ ០០០ រៀល | ៥៥ | ៥.៧៤ |
| ៦ | ចន្លោះពី ៥០០ ០០០ ទៅ ៦០០ ០០០ រៀល | ៤២ | ៤.៣៨ |
| ៧ | ចន្លោះពី ៤០០ ០០០ ទៅ ៥០០ ០០០ រៀល | ២៤ | ២.៥១ |
| ៨ | ចន្លោះពី ៣០០ ០០០ ទៅ ៤០០ ០០០ រៀល | ២១ | ២.១៩ |
| ៩ | ចន្លោះពី ២០០ ០០០ ទៅ ៣០០ ០០០ រៀល | ១៣ | ១.៣៦ |
| ១០ | ចន្លោះពី ១០០ ០០០ ទៅ ២០០ ០០០ រៀល | ៧ | ០.៧៣ |
| ១១ | តិចជាង ១០០ ០០០ រៀល | ៦ | ០.៦៣ |
| ១២ | គ្មានចំណូល | ៤ | ០.៤២ |
| សរុប | | ៩៥៨ | ១០០% |

បន្ទាប់ពីមានការផ្ទុះ និងរីករាលដាលនៃជំងឺកូវីដ-១៩ ជាង បីភាគបួន នៃអ្នកចូលរួមផ្តល់បទសម្ភាសក្នុងការសិក្សានេះ (ឬ ៨១%) បាននិយាយប្រាប់ថាចំណូលគ្រួសាររបស់ពួកគេរងផលប៉ះពាល់យ៉ាងខ្លាំង (សូមមើលក្រាហ្វិចទី៩)។

ក្រាហ្វិចទី៩៖ ចំណូលគ្រួសារដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩




ការស្ទង់មតិនេះ បង្ហាញយ៉ាងច្បាស់ថាប្រភពចំណូលក្នុងគ្រួសារក្រីក្រនៅក្នុងទីក្រុងបានធ្លាក់ចុះជារួម ប៉ុន្តែមិនចំពោះគ្រប់ក្រុមគ្រួសារឡើយ។ ដូចមានបង្ហាញក្នុងតារាងទី ១៤ ដែលធ្លាប់រកចំណូលបានលើស ២ លានរៀលក្នុងមួយខែ មានចំណូលធ្លាក់ចុះពី ជិត៣១% មុនពេលមានជំងឺកូវីដ-១៩ សល់ត្រឹមជាង ៥% ចាប់តាំងពីពេលនោះមក។ ដូចគ្នានេះផងដែរ សម្រាប់គ្រួសារដែលរកចំណូលបានចន្លោះពី ១ លាន ទៅ ២ លានរៀលក្នុងមួយខែនោះ មុនមានជំងឺកូវីដ ចំណូលរបស់ពួកគេបានធ្លាក់ចុះពី ជាង ៣១% សល់ត្រឹមតែជាង ២១% ប៉ុណ្ណោះ។

ទោះជាយ៉ាងនេះក្តី ចំពោះគ្រួសារដែលរកចំណូលបានពី ៨00 000 ទៅ ១ 000 000 រៀលក្នុងមួយខែ ពីមុនឃើញមានចំនួនកើនឡើងពីជាង ១២% ដល់ជាង១៨%។ ខណៈដែលគ្រួសារដែលធ្លាប់រកចំណូលបានពី ៧00 000 ទៅ ៨00 000 រៀល ក្នុងមួយខែ ក៏មានចំនួនកើនឡើងពីជាង ៨% ទៅជិត ១១%។

ការសម្ភាសជាមួយអ្នកដឹកនាំសហគមន៍មួយចំនួនបានឱ្យដឹងថា បុគ្គលិករដ្ឋ និងកម្មកររោងចក្រអាចមិនរងផលប៉ះពាល់ ឬរងផលប៉ះពាល់តិចតួចលើប្រាក់ចំណូលក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩។

តារាងទី ៥៖ កម្រិតចំណូលក្នុងមួយខែនៅក្នុងអំឡុងពេលផ្ទុះឡើងនៃជំងឺកូវីដ-១៩

| ល.រ | បរិយាយ | ចំនួន | % |
|---|---|---|---|
| ១ | ចន្លោះពី ១ 000 000 ទៅ ២ 000 000 រៀល | ១៦៦ | ២១.១៧ |
| ២ | ចន្លោះពី ៨00 000 ទៅ ១ 000 000 រៀល | ១៤២ | ១៨.១១ |
| ៣ | ចន្លោះពី ៧00 000 ទៅ ៨00 000 រៀល | ៨៦ | ១0.៩៧ |
| ៤ | គ្មានចំណូល | ៨២ | ១0.៤៦ |
| ៥ | ចន្លោះពី ៥00 000 ទៅ ៦00 000 រៀល | ៥៧ | ៧.២៧ |
| ៦ | ចន្លោះពី ៦00 000 ទៅ ៧00 000 រៀល | ៥៩ | ៧.៥៣ |
| ៧ | ចន្លោះពី ៣00 000 ទៅ ៤00 000 រៀល | ៤៤ | ៥.៦១ |
| ៨ | ចន្លោះពី ១00 000 ទៅ ២00 000 រៀល | ៣៦ | ៤.៥៩ |
| ៩ | ចន្លោះពី ៤00 000 ទៅ ៥00 000 រៀល | ៣៨ | ៤.៨៥ |
| ១0 | លើស ២ 000 000 រៀល | ៤២ | ៥.៣៦ |
| ១១ | ចន្លោះពី ២00 000 ទៅ ៣00 000 រៀល | ២៧ | ៣.៤៤ |
| ១២ | តិចជាង ១00 000 រៀល | ៥ | 0.៦៤ |
| សរុប | | ៧៨៤ | ១00% |

ក្នុងចំណោមគ្រួសារដែលត្រូវបានសម្ភាស មានប្រមាណ ៣០% រស់នៅតាមបណ្តោយផ្លូវនៅក្នុង ឬជុំវិញរាជធានីភ្នំពេញ។ កាន់តែគួរឱ្យចាប់អារម្មណ៍នោះ មានជាង ១៧% រស់នៅតាមមាត់ទន្លេជិត ១៤% រស់នៅតាមផ្លូវរថភ្លើង និងជាង ១៣% រស់នៅតាមបណ្តោយប្រឡាយបង្ហូរទឹកស្អុយ។

តារាងទី ៦៖ ទីតាំងគ្រួសារនៅក្នុងសហគមន៍[២១]

| ល.រ | បរិយាយ | ចំនួន | % |
|---|---|---|---|
| ១ | តាមបណ្តោយផ្លូវ | ២៨៦ | ២៩.៨៥ |
| ២ | តាមមាត់ទន្លេ | ១៦៤ | ១៧.១២ |
| ៣ | តាមផ្លូវរថភ្លើង | ១៣១ | ១៣.៦៧ |
| ៤ | តាមប្រឡាយបង្ហូរទឹកស្អុយ | ១២៦ | ១៣.១៥ |
| ៥ | នៅលើដីរដ្ឋ | ១១៩ | ១២.៤២ |
| ៦ | នៅលើបឹង | ៩៧ | ១០.១៣ |
| ៧ | នៅលើដីជាកម្មសិទ្ធិរបស់អ្នកផ្សេង | ៣១ | ៣.២៤ |
| ៨ | ក្រោមដំបូងអាគារ | ៣ | 0.៣១ |
| ៩ | ក្នុងចេតិយវត្ត | ១ | 0.១0 |
| សរុប | | ៩៥៨ | ១00% |

ជិត ៨៣% នៃអ្នកចូលរួមផ្តល់បទសម្ភាសមិនបានផ្លាស់ពីទីលំនៅគោលរបស់ពួកគេក្នុងអំឡុងពេល ៥ ឆ្នាំកន្លងមកនេះនោះទេ(សូមមើលតារាងទី ១៦)។ ក្នុងចំណោមអ្នកដែលធ្លាប់បានផ្លាស់ទីលំនៅទាំងនោះ មានជិត ៦១% ធ្លាប់ផ្លាស់ទីលំនៅតែម្តងគត់ ជាង៣២% ធ្លាប់ផ្លាស់ទីលំនៅពីរដង និងជាងង ៤% នៃអ្នកចូលរួមផ្តល់បទសម្ភាសបានផ្លាស់ប្តូរទីលំនៅលើសពី បីដង (សូមមើលក្រាហ្វិច១០)។ មូលហេតុនៃការផ្លាស់ទីលំនៅមានសិក្សាបន្ថែមនៅខាងក្រោម។

ក្រាហ្វិចទី១០៖ ការផ្លាស់ទីលំនៅរបស់គ្រួសារក្នុងអំឡុងពេល ៥ឆ្នាំកន្លងមក




ក្រាហ្វិចទី១១៖ តើគ្រួសារបានផ្លាស់ប្តូរផ្ទះសម្បែងរបស់ពួកគេញឹកញាប់ប៉ុណ្ណាក្នុងអំឡុងពេល ៥ឆ្នាំកន្លងមកនេះ?




[២១] បញ្ជីឈ្មោះនៅក្នុងតារាងសំដៅលើទីតាំងសហគមន៍តែប៉ុណ្ណោះ និងមិនមែនជាចំណាត់ថ្នាក់នៃប្រភេទដីនោះទេ (ដូចជាដីរដ្ឋ ឬដីឯកជន ជាដើម)

ក្នុងចំណោមអ្នកចូលរួមផ្តល់បទសម្ភាសចំនួន ១៦៥ នាក់ ដែលធ្លាប់ផ្លាស់ទីលំនៅក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ មានជាង ៣៥% បាននិយាយថាពួកគេត្រូវបានអាជ្ញាធរបង្ខំឱ្យចេញ។ នេះបង្ហាញថាការអនុវត្តការបណ្តេញចេញ និងការផ្លាស់ទីលំនៅអាចចូលរួមចំណែកផ្លាស់ប្តូរចំនួននៃប្រជាពលរដ្ឋក្នុងសហគមន៍ក្រីក្រនៅក្នុងទីក្រុង។ ជិត២៧% ទៀតបានសម្រេចចាកចេញដោយសារកត្តាសេដ្ឋកិច្ចដូចជាដើម្បីស្វែងរកការងារ ហើយ ៣៨% បានផ្លាស់ទីលំនៅព្រោះតែហេតុផល"ផ្សេងទៀត" រួមទាំងដើម្បីរស់នៅជុំគ្នាជាមួយសមាជិកគ្រួសាររបស់ពួកគេ។

ក្រាហ្វិចទី១២៖ ហេតុផលនៃការផ្លាស់ទីលំនៅ (សម្រាប់ការផ្លាស់ទីលំនៅលើកចុងក្រោយតែប៉ុណ្ណោះ)





### គ. លំនៅឋាន

របាយការណ៍នេះក៏អង្កេតមើលលើស្ថានភាពលំនៅឋានរបស់អ្នកចូលរួមផ្ដល់បទសម្ភាសផងដែរ។ ភាគច្រើន ជាង ៧៥% នៃអ្នកចូលរួមផ្ដល់បទសម្ភាស បានអះអាងថាមានផ្ទះជារបស់ផ្ទាល់ខ្លួន[២២] ខណៈដែល ជិត ២២% ផ្សេងទៀតជួលផ្ទះស្នាក់នៅ ឬស្នាក់នៅជាមួយសាច់ញាតិ ឬមិត្តភក្តិ (សូមមើលក្រាហ្វិចទី១៣)។ សំណួរស្រាវជ្រាវមួយក៏ត្រូវបានបង្កើតឡើងដើម្បីសិក្សាឈ្វេងយល់បន្ថែមពីប្រភពប្រាក់សម្រាប់សង់លំនៅឋាន។ ក្នុងបរិបទនេះ ជាង ៥៣% បាននិយាយថាបានប្រើប្រាស់ប្រាក់ផ្ទាល់ខ្លួនដើម្បីទិញសម្ភារៈ និងសង់លំនៅឋានរបស់ពួកគេ។ ជាង៣១% ផ្សេងទៀតបានរាយការណ៍ថាខ្ចីប្រាក់ពីធនាគារ ឬស្ថាប័នផ្សេងទៀត។ ចុងក្រោយ មាន ជិត ១១% នៃអ្នកចូលរួមផ្ដល់បទសម្ភាសបានយកប្រាក់កម្ចីពីសាច់ញាតិរបស់ពួកគេ (សូមមើលក្រាហ្វិចទី ១៤ ខាងក្រោម)។

ក្រាហ្វិចទី១៣៖ ស្ថានភាពស្នាក់នៅរបស់អ្នកចូលរួមផ្ដល់បទសម្ភាស




ក្រាហ្វិចទី១៤៖ ប្រភពប្រាក់សម្រាប់សាងសង់លំនៅឋាន




ស្ថានភាពផ្ទះរបស់អ្នកចូលរួមក្នុងការសិក្សានេះ ទាំងសម្រាប់គ្រួសារដែលមានផ្ទះផ្ទាល់ខ្លួន និងគ្រួសារដែលស្នាក់នៅផ្ទះជួល ក៏ត្រូវបានសង្កេតមើលផងដែរ។ តាមការសង្កេត និងការពិភាក្សាជាមួយអ្នកចូលរួមផ្ដល់បទសម្ភាស សំខាន់បានឱ្យដឹងថាប្រមាណជាពាក់កណ្ដាល (ឬ ៥០%) នៃអ្នកចូលរួមផ្ដល់បទសម្ភាសរស់នៅក្នុងផ្ទះដែលសង់ពីឈើ និងមានដំបូលប្រក់ស័ង្កសី។

ក្រាហ្វិចទី១៥៖ ស្ថានភាពលំនៅឋានរបស់គ្រួសារ




ប្រហែលជា ពីរភាគបីនៃអ្នកចូលរួមផ្ដល់បទសម្ភាស ជិត ៦២% ពេញចិត្តនឹងទំហំផ្ទះ ដែលធំទូលាយសម្រាប់សមាជិកគ្រួសារទាំងអស់។ ជិត ៣០% ផ្សេងទៀតបានឆ្លើយប្រាប់ថាមានអារម្មណ៍ចង្អៀត ហើយតិចជាង ៩% មានអារម្មណ៍ថាពួកគេរស់នៅក្នុងភាពចង្អៀតខ្លាំង។

ក្រាហ្វិចទី១៦៖ ទំហំ ឬទីកន្លែងក្នុងលំនៅឋាន




[២២] មានផ្ទះផ្ទាល់ខ្លួនមិនសំដៅថាមានប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីនោះទេ។ ពួកគេមានផ្ទះដែលសង់លើដីរដ្ឋ។
[២៣] សំដៅលើការចង្អៀត



## ឃ. ឯកសារគ្រួសារ

ឯកសារគ្រួសារមានសារៈសំខាន់ចាំបាច់បំផុតសម្រាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។ ជាទូទៅ ឯកសារគ្រួសាររួមមានសៀវភៅគ្រួសារ សៀវភៅស្នាក់នៅ និងអត្តសញ្ញាណប័ណ្ណ។ ប្រសិនបើគ្មានឯកសារទាំងនេះទេ គ្រួសារនឹងមិនអាចបោះឆ្នោត ឬចុះឈ្មោះស្នើសុំប័ណ្ណសមធម៌ និងធ្វើអ្វីសំខាន់ផ្សេងទៀតបានឡើយ។ ប៉ុន្តែ ផ្អែកលើលទ្ធផលនៃការស្ទង់មតិនេះ មានត្រឹមតែជាង ៥៣% នៃអ្នកចូលរួមផ្តល់បទសម្ភាសប៉ុណ្ណោះមានសៀវភៅគ្រួសារ។ ជាង៤៧% ទៀតបានប្រាប់ថាមិនទាន់មានសៀវភៅគ្រួសារនៅឡើយ (សូមមើលក្រាហ្វិចទី១៧)។ មានចម្ងល់ផ្សេងៗជុំវិញភាគរយដ៏ខ្ពស់នៃចំនួនប្រជាពលរដ្ឋដែលមិនមានសៀវភៅគ្រួសារនេះ[២៤]។

ក្រាហ្វិចទី១៧៖ តើគ្រួសារអ្នកមានសៀវភៅគ្រួសារដែរឬអត់?




ការឆ្លើយតបរបស់ប្រជាពលរដ្ឋដែលគ្មានសៀវភៅគ្រួសារទាំងនោះបានបង្ហាញឱ្យដឹងបន្ថែមទៀតថា ភាគច្រើនជាង ៧៥% នៅមិនទាន់បានទៅរកមន្ត្រីពាក់ព័ន្ធដើម្បីចុះឈ្មោះស្នើសុំសៀវភៅគ្រួសារនៅឡើយ (សូមមើលក្រាហ្វិច១៨)។

ក្រាហ្វិចទី១៨៖ មូលហេតុដែលមិនមានសៀវភៅគ្រួសារ




ស្រដៀងគ្នានឹងសៀវភៅគ្រួសារដែរ មានប្រមាណ ២៣% នៃអ្នកចូលរួមផ្តល់បទសម្ភាសគ្មានសៀវភៅស្នាក់សម្រាប់គ្រួសារ (សូមមើលតារាងទី ២៥ ខាងក្រោម)។ តួលេខនេះមិនស្របទៅនឹងការរកឃើញខាងលើពីសៀវភៅគ្រួសារនោះទេ។ គួរបញ្ជាក់ផងដែរថា ប្រសិនជាគ្មានសៀវភៅគ្រួសារទេ គ្រួសារមួយមិនអាចធ្វើសៀវភៅស្នាក់នៅបានឡើយ។ លើសពីនេះទៀត ប្រសិនបើគ្មានសៀវភៅគ្រួសារ គ្រួសារមិនអាចទទួលបានប័ណ្ណសមធម៌ ឬបំពេញគ្រប់តម្រូវការផ្នែករដ្ឋបាលរបស់រដ្ឋបានឡើយ។[២៥] ជាមួយគ្នានេះផងដែរ សៀវភៅស្នាក់នៅមិនមែនជាតម្រូវការចាំបាច់សម្រាប់តម្កល់ដើម្បីធានាកម្ចីឡើយ ដូច្នេះឯកសារនេះអាចមាននៅជាមួយគ្រួសារ។ បើសិនជាការសន្មតអំពីកម្ចីខាងលើនេះពិតជាត្រឹមត្រូវនោះ គេអាចសន្មតបានថាអ្នកចូលរួមផ្តល់បទសម្ភាសភាគច្រើននឹងមានសៀវភៅស្នាក់នៅនៅក្នុងដៃរបស់ពួកគេ។ នេះបង្ហាញថាទិន្នន័យនៃគ្រួសារមានសៀវភៅគ្រួសារអាចមិនត្រឹមត្រូវព្រោះតែការមិនជឿទុកចិត្ត ដោយសារសៀវភៅគ្រួសារទាំងនេះត្រូវបានប្រើប្រាស់ដើម្បីយកកម្ចី។

ក្រាហ្វិចទី១៩៖ តើអ្នកមានសៀវភៅស្នាក់នៅដែរឬអត់?




---

[២៤] កម្រិតភាគរយនៃអ្នកឆ្លើយតបថាគ្មានសៀវភៅគ្រួសារនេះដូចជាខ្ពស់និងអាចលើសពីការពិតដោយសារពួកគេមិនចង់ប្រាប់ការពិតទាក់ទងនឹងការដាក់បញ្ចាំសៀវភៅគ្រួសារជាថ្នូរយកប្រាក់កម្ចីរបស់ពួកគេ

[២៥] ជាធម្មតាសៀវភៅស្នាក់នៅមិនត្រូវការសម្រាប់តម្កល់ធានាកម្ចីទេ ដូចនេះវាអាចមាននៅក្នុងគ្រួសារ


ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

សៀវភៅគ្រួសារ
FAMILY RECORD BOOK

នាមត្រកូល-នាមខ្លួន
SURNAME AND NAME

No


ព្រះរាជាណាចក្រកម្ពុជា
ROYAUME DU CAMBODGE
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION ROI

សៀវភៅស្នាក់នៅ
CARNET DE RESIDENCE

នាមត្រកូល.នាមខ្លួន
NOM ET PRENOM
ផ្ទះលេខ ផ្លូវ ក្រុម
CHEZ . N° VOIE GROUPE
ភូមិ . មណ្ឌល
VILLAGE
ឃុំ . សង្កាត់
COMMUNE QUARTIER
ក្រុង . ស្រុក . ខណ្ឌ
VILLE . DISTRICT
រាជធានី . ខេត្ត
CAPITALE . PROVINCE
ថ្ងៃទី ខែ ឆ្នាំ
LE

លេខ
N°
ប.ក្បាលទី ទំព័រ
REGISTRE. N° PAGE

## ង. ការទទួលបានសេវាថែទាំសុខភាព

ការទទួលបានសេវាថែទាំសុខភាពក៏ត្រូវបានសិក្សាដោយការស្ទង់មតិនេះផងដែរ។ ដូចអ្វីដែលបានរកឃើញ ១៤%នៃចំនួនអ្នកចូលរួមផ្តល់បទសម្ភាសសរុបបានប្រាប់ថាពួកគេមានកូនអាយុក្រោម ១២ ខែនៅក្នុងគ្រួសារ (សូមមើលក្រាហ្វិចទី ១៩)។ ប្រមាណ ៨២% នៃអ្នកចូលរួមផ្តល់បទសម្ភាសបានបញ្ជាក់ថាកូនរបស់ពួកគេទទួលបានការចាក់វ៉ាក់សាំងគ្រប់គ្រាន់ ខណៈដែលជាង ១៦% ផ្សេងទៀតខកខានមិនបានចាក់វ៉ាក់សាំងមួយចំនួន ហើយប្រហែលជាមានតែ ១,៤៨% តែប៉ុណ្ណោះ ដែលមិនទទួលបានការចាក់វ៉ាក់សាំងទាល់តែសោះ (សូមមើលក្រាហ្វិចទី ២០)។ ដូចបានបញ្ជាក់ពីអ្នកដឹកនាំសហគមន៍ កុមារដែលមិនទទួលបានការចាក់វ៉ាក់សាំង ឬទទួលបានការចាក់វ៉ាក់សាំងមិនគ្រប់ចំនួននោះ អាចមកពីគ្រួសារដែលមិនស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងភូមិ ឬគ្រួសារដែលសម្រេចចិត្តមិនចាក់វ៉ាក់សាំង។[២៦]

ក្រាហ្វិចទី២០៖ គ្រួសារមានកូនអាយុក្រោម ១២ខែ




ក្រាហ្វិចទី២១៖ តើក្មេងទាំងនេះបានចាក់វ៉ាក់សាំងហើយឬនៅ?




គ្រួសារស្ទើរតែទាំងអស់ (៩៦%) បានបញ្ជាក់ប្រាប់ថាពួកគេរក្សាទុកប័ណ្ណចាក់វ៉ាក់សាំងពណ៌លឿងរបស់ពួកគេនៅឯផ្ទះ (សូមមលើក្រាហ្វិចទី ២២)។

ក្រាហ្វិចទី២២៖ តើនៅរក្សាទុកកាតលឿងក្នុងគ្រួសារដែរឬទេ?




មានតែជិត ៤% នៃអ្នកចូលរួមផ្តល់បទសម្ភាសប៉ុណ្ណោះមានស្ត្រីមានផ្ទៃពោះនៅក្នុងគ្រួសារក្នុងពេលនៃការស្ទង់មតិនេះ (សូមមើលក្រាហ្វិចទី ២៣)។ អាចនិយាយបានថា តួលេខនេះមានកម្រិតទាបសម្រាប់ស្ត្រីមានផ្ទៃពោះ។ នេះប្រហែលជាលទ្ធផលនៃការអនុវត្តការពន្យារកំណើតបានល្អ។ ការសម្ភាសជាមួយអ្នកដឹកនាំសហគមន៍បញ្ជាក់ឱ្យដឹងថាស្ត្រីពពោះភាគច្រើនស្គាល់ច្បាស់ពីវិធីសាស្ត្រពន្យារកំណើតតាមរយៈការអប់រំផ្នែកសុខភាពដែលផ្តល់ដោយមណ្ឌលសុខភាពក្នុងមូលដ្ឋាន ឬអង្គការមិនមែនរដ្ឋាភិបាល។

ទោះបីជាយ៉ាងនេះក្តី នៅពេលសាកសួរថាតើស្ត្រីមានផ្ទៃពោះទទួលបានការថែទាំសុខភាពដែរឬទេ ប្រមាណជាជិត៨២%បានពន្យល់ប្រាប់ថាពួកគេទៅមណ្ឌលសុខភាពជាប្រចាំ ខណៈដែលមានជាង ១៣% ទៅមិនសូវជាទៀងទាត់។

ក្រាហ្វិចទី២៣៖ តើមានស្ត្រីមានផ្ទៃពោះក្នុងគ្រួសារដែរឬទេ?




[២៦] ក្នុងក្រាហ្វិចទី ៣១ បានបង្ហាញឱ្យដឹងថា ប្រមាណ ២២% នៃអ្នកឆ្លើយតបមិនបានទៅសាលារៀន ហើយភស្តុតាងផ្សេងទៀតបានចង្អុលបង្ហាញថា ទំនាក់ទំនងរវាងគ្រួសារក្រីក្រនៅទីក្រុងនិងសេវាថែទាំសុខភាពរបស់រដ្ឋពេលខ្លះនៅមានភាពខ្វះខាត

ក្រាហ្វិចទី២៤៖ ភាពញឹកញាប់នៃការទៅមណ្ឌលសុខភាពរបស់ស្ត្រីមានផ្ទៃពោះ




មណ្ឌលសុខភាពរដ្ឋត្រូវបានជឿទុកចិត្តដោយសហគមន៍ចំពោះសេវាថែទាំសុខភាពមាតា និងកុមារ។ ដូចដែលការស្ទង់មតិនេះបានកំណត់ឃើញ រហូតដល់ជិត ៧៣% នៃអ្នកចូលរួមផ្តល់បទសម្ភាសបានរៀបរាប់ប្រាប់លម្អិតថាស្ត្រីទៅមណ្ឌលសុខភាពក្នុងមូលដ្ឋានច្រើនជាងទៅមន្ទីរពេទ្យឯកជន[២៧] (១៣%)។ នេះប្រហែលជាមកពីភាពខុសគ្នាក្នុងតម្លៃ ហើយអាចមិនឆ្លុះបញ្ចាំងអំពីទំនុកចិត្តលើមណ្ឌលសុខភាពរដ្ឋនោះទេ។

ក្រាហ្វិចទី២៥៖ តើស្ត្រីមានផ្ទៃពោះទាំងនេះទៅពិនិត្យសុខភាពនៅកន្លែងណា?




ព្រោះតែការរីករាលដាលនៃជំងឺកូវីដ-១៩ ការស្ទង់មតិក៏បានពិនិត្យមើលកម្រិតនៃការចាក់វ៉ាក់សាំងក្នុងចំណោមអ្នកចូលរួមផ្តល់បទសម្ភាសផងដែរ។ ជិត ៨៥% នៃអ្នកចូលរួមផ្តល់បទសម្ភាសបានទទួលបានការចាក់វ៉ាក់សាំង (សូមមើលក្រាហ្វិចទី ២៦)។ ក្នុងចំណោមអ្នកទាំងនោះ ជិត៨៤% បានចាក់វ៉ាក់សាំងចំនួនពីរដង ហើយ ជិត១១% បានចំនួនបីដង។ មានតែ ជិត ៦% ប៉ុណ្ណោះបានចាក់វ៉ាក់សាំងបានម្តងគត់ (សូមមើលក្រាហ្វិចទី២៧)។[២៨] តួលេខនេះហាក់ដូចជាស្របនឹងកិច្ចខិតខំរបស់រាជរដ្ឋាភិបាលក្នុងការជំរុញឱ្យមានការចាក់វ៉ាក់សាំងនៅក្នុងរាជធានីភ្នំពេញ។

ក្រាហ្វិចទី២៦៖ តើអ្នកបានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ហើយឬនៅ?




ក្រាហ្វិចទី២៧៖ តើអ្នកបានចាក់វ៉ាក់សាំងការពារមេរោគកូវីដ-១៩ ប៉ុន្មានដងហើយ?




[២៧] ក្នុងភាពជាក់ស្តែង ស្ត្រីមកពីគ្រួសារមានសេដ្ឋកិច្ចល្អប្រសើរហាក់ដូចជាធ្វើការពិនិត្យមើលគភ៌ និងបង្កើតកូននៅពេទ្យឯកជន/សម្ភពច្រើនជាងនៅមណ្ឌលសុខភាពរដ្ឋ

[២៨] ចំនួនប្រជាជនដែលមិនទទួលបានការចាក់វ៉ាក់សាំងអាចប្រែប្រួលក្រោយការចុះស្ទង់មតិបានបញ្ចប់ ដោយសាររដ្ឋាភិបាលបន្តជំរុញការចាក់វ៉ាក់សាំងដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ដែលរស់នៅក្នុងទីក្រុងភ្នំពេញ និងនៅទូទាំងប្រទេស

មូលហេតុនៃការមិនទទួលបានការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ក៏ត្រូវបានស្រាវជ្រាវផងដែរ។ ក្នុងចំណោមអ្នកដែលមិនបានចាក់វ៉ាក់សាំង ជាង ៩២% បានលើកឡើងដោយសារបញ្ហាសុខភាព ខណៈដែលប្រមាណ ៦% មានការភ័យខ្លាច ហើយជាង ២% និយាយថាពួកគេមានការមមាញឹកខ្លាំង (សូមមើលក្រាហ្វិចទី ២៨)។

ក្រាហ្វិចទី២៨៖ មូលហេតុដែលមិនបានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩



## ច. ការអប់រំរបស់កុមារ

ការស្ទង់មតិព្យាយាមវាយតម្លៃកម្រិតនៃការអប់រំរបស់កុមារនៅគ្រប់កម្រិត រួមមានថ្នាក់មត្តេយ្យ បឋមសិក្សា និងវិទ្យាល័យ។ ប្រមាណ ៣០% នៃអ្នកចូលរួមផ្តល់បទសម្ភាសមានកូនអាយុចន្លោះពី ៣ ទៅ ៥ ឆ្នាំក្នុងក្រុមគ្រួសារ (សូមមើលក្រាហ្វិចទី ២៩)។ ក្នុងនោះជិត ១៤% នៃអ្នកចូលរួមផ្តល់បទសម្ភាសទាំងនោះបានបញ្ជូនកូនទៅសាលាមត្តេយ្យ (សូមមើលតារាងទី ៣៦)។ អ្នកចូលរួមផ្តល់បទសម្ភាសបានពន្យល់ពីហេតុផលដែលមិនបានបញ្ជូនក្មេងទៅសាលាមត្តេយ្យ ដែលជាង ៧៦% បានលើកឡើងថាកូនរបស់ពួកគេនៅតូចពេកមិនគួរនៅឆ្ងាយពីគ្រួសារ ខណៈដែល ជិត ៣% បាននិយាយថាពួកគេមមាញឹកពេក ឬមិនមានលទ្ធភាពបញ្ជូនក្មេងទៅរៀននៅសាលាមត្តេយ្យ (សូមមើលក្រាហ្វិចទី ៣០)។

ក្រាហ្វិចទី២៩៖ គ្រួសារដែលមានក្មេងអាយុពី ៣ ទៅ ៥ឆ្នាំ




ក្រាហ្វិចទី៣០៖ ក្មេងអាយុពី ៣ ទៅ ៥ឆ្នាំដែលទៅសាលាមត្តេយ្យ




ក្រាហ្វិចទី៣១៖ ហេតុផលដែលមិនបញ្ជូនក្មេងទៅសាលាមត្តេយ្យ?




ប្រហែលជាង ៤៥% នៃអ្នកចូលរួមផ្តល់បទសម្ភាសមានកូនអាយុពី ៦ ទៅ ១១ ឆ្នាំនៅក្នុងគ្រួសារ។ លើសពី ៩០% នៃកុមារទាំងនេះទៅរៀននៅសាលាជាប្រចាំ ខណៈដែលមានតិចជាង ១% បានបោះបង់ការសិក្សាក្រោយពីចុះឈ្មោះហើយ និងជិត ៩% ទៀតមិនធ្លាប់ទៅរៀននៅសាលា (សូមមើលតារាងទី ៣៩)។ គួរឱ្យចាប់អារម្មណ៍ផងដែរ។

ខណៈដែលមានកុមារជាច្រើនទៅរៀននៅសាលារដ្ឋ មានជាង ៨% នៃអ្នកចូលរួមផ្តល់បទសម្ភាសបញ្ជូនកូនរបស់ពួកគេទៅរៀននៅសាលាឯកជន (សូមមើលតារាងទី ៣៩ និង ៤០)។ ការពិគ្រោះយោបល់ជាមួយអ្នកដឹកនាំសហគមន៍បានឱ្យឃើញថាគ្រួសារខ្លះជាអ្នកមានទ្រព្យគ្រប់គ្រាន់ឱ្យកូនរបស់ពួកគេរៀននៅសាលាឯកជនបាន ខណៈដែលកុមារដែលមិនទៅរៀនភាគច្រើនមកពីគ្រួសារក្រីក្រដែលផ្លាស់ទីលំនៅញឹកញាប់។

ក្រាហ្វិចទី៣២៖ មានក្មេងដែលមានអាយុចន្លោះពី ៦ ទៅ ១១ ឆ្នាំ



## ក្រាហ្វិចទី៣៣៖ កម្រិតនៃកុមារអាយុពី ៦ ទៅ ១១ ឆ្នាំដែលទៅរៀននៅសាលាបឋម




## ក្រាហ្វិចទី៣៤៖ តើសាលាមួយណាដែលកូនរបស់ពួកគេទៅរៀន?




## ក្រាហ្វិចទី៣៥៖ ក្មេងអាយុពី ១២ ទៅ ១៤ ឆ្នាំនៅក្នុងក្រុមគ្រួសារ




## ក្រាហ្វិចទី៣៦៖ តើមានក្មេងទៅរៀននៅអនុវិទ្យាល័យ ឬ វិទ្យាល័យដែរឬអត់?




## ក្រាហ្វិចទី៣៧៖ ហេតុផលដែលមិនអាចទៅសាលារៀន




ប្រមាណ ៣០% នៃអ្នកចូលរួមផ្តល់បទសម្ភាសដែលមានកូនអាយុពី ១២ ទៅ ១៤ឆ្នាំ នោះ មាន ៩៣% នៃកុមារក្នុងក្រុមអាយុនេះបានទៅសាលារៀនជាទៀងទាត់ ខណៈដែលប្រមាណ ៦% បានបោះបង់ការសិក្សា ហើយក្រោម ២% មិនដែលទៅរៀននៅសាលា (សូមមើលក្រាហ្វិចទី ៣៥ និងក្រាហ្វិច ៣៦)។ ហេតុផលផ្សេងៗជាច្រើនត្រូវបានលើកឡើងអំពីការមិនបញ្ជូនកូនទៅសាលារៀន ដែលរួមមានការមិនមានប្រាក់គ្រប់គ្រាន់សម្រាប់ថ្លៃសិក្សា (៥០%) និងការរៀនមិនទាន់ក្មេងដទៃទៀត (១១%) (សូមមើលក្រាហ្វិចទី ៣៧)។


SPEED
SPEED

## ឆ. ភាពងាយរងគ្រោះនៅក្នុងគ្រួសារ

ការស្ទង់មតិនេះ ក៏បានបង្ហាញនូវភាពងាយរងគ្រោះមួយចំនួននៅក្នុងគ្រួសារ។ បញ្ហានៃភាពងាយរងគ្រោះទាំងនេះ រួមមានដូចជាសមាជិកគ្រួសារធ្វើការងារដែលមានហានិភ័យខ្ពស់ កុមារកំព្រា និងក្មេងដែលត្រូវបានគេបោះបង់ចោល កុមារដែលខ្វះសារជាតិចិញ្ចឹមក្នុងខ្លួន និងកុមារដែលពិការផ្នែករូបរាងកាយ និងផ្លូវចិត្ត។ គ្រួសារប្រមាណជិត ៣% មានសមាជិកធ្វើការងារមានហានិភ័យខ្ពស់ (សូមមើលក្រាហ្វិចទី ៣៨)។ ការងារទាំងនេះ រួមមានការងាររើសអេតចាយពេលយប់ (ដែលប្រឈមនឹងគ្រោះថ្នាក់ចរាចរណ៍) និងបេះបន្លែនៅក្នុងបឹង (ដែលប្រឈមនឹងការលង់ទឹក)។

ក្រាហ្វិចទី៣៨៖ តើមានសមាជិកគ្រួសារធ្វើការងារមានហានិភ័យខ្ពស់ឬទេ?




គ្រួសារប្រមាណជាង ៥% មានក្មេងកំព្រា និងក្មេងដែលត្រូវបានគេបោះបង់ចោល រស់នៅជាមួយ (សូមមើលក្រាហ្វិចទី ៣៩)។ យោងតាមការពិភាក្សាជាមួយក្រុមគ្រួសារ និងអ្នកដឹកនាំសហគមន៍ កុមារទាំងនេះ គឺជាកូនប្រុសឬស្រីរបស់បងប្អូនរបស់ពួកគេ ដែលឪពុកម្តាយបានស្លាប់ចោល ឬបោះបង់ពួកគេចោល។

ក្រាហ្វិចទី៣៩៖ តើមានក្មេងកំព្រា ឬក្មេងដែលត្រូវបានគេបោះបង់ចោល រស់នៅជាមួយក្នុងគ្រួសារឬទេ?




រោគសញ្ញានៃកុមារដែលខ្វះសារជាតិចិញ្ចឹម មានដូចជាសក់ស្តើងហើយក្រហម ក្បាលពោះធំ ស្គមស្គាំង និងស្បែកស្លេកស្លាំង។ ប៉ុន្តែមានតែជាង ២% ប៉ុណ្ណោះ ដែលបាននិយាយថាមានកុមារប្រភេទនេះនៅក្នុងក្រុមគ្រួសាររបស់ពួកគេ (សូមមើលក្រាហ្វិចទី ៤០)។ ការរកឃើញនេះបានបញ្ជាក់ថា កុមារកាន់តែច្រើនទទួលបានសារជាតិចិញ្ចឹមគ្រប់គ្រាន់។

ក្រាហ្វិចទី៤០៖តើមានក្មេងដែលខ្វះ ឬមានសារជាតិចិញ្ចឹមមិនគ្រប់គ្រាន់ នៅក្នុងក្រុមគ្រួសារអ្នកឬទេ?



ប្រមាណ ៥% នៃអ្នកចូលរួមផ្តល់បទសម្ភាសមានសមាជិកគ្រួសារ (កុមារ) ដែលមានពិការភាព (សូមមើលក្រាហ្វិច៤១)។

ក្រាហ្វិចទី៤១៖ តើមានកុមារដែលពិការរាងកាយ និងផ្លូវចិត្ត នៅក្នុងគ្រួសារអ្នកឬទេ?




ជាងពាក់កណ្តាលនៃអ្នកចូលរួមផ្តល់បទសម្ភាស (៥៤%) បាននិយាយថាធ្លាប់ឃើញមនុស្សប្រើប្រាស់ថ្នាំញៀននៅក្នុងសហគមន៍របស់ពួកគេ (សូមមើលក្រាហ្វិចទី ៤២)។

ក្រាហ្វិចទី៤២៖ តើអ្នកធ្លាប់ឃើញមានមនុស្សប្រើប្រាស់ថ្នាំញៀន នៅក្នុងសហគមន៍របស់អ្នកឬទេ?




ជិត ១៩% នៃអ្នកចូលរួមផ្តល់បទសម្ភាសមានសមាជិកគ្រួសារដែលមានជំងឺរ៉ាំរ៉ៃ (សូមមើលក្រាហ្វិចទី ៤៣)។ អ្នកដែលមានជំងឺរ៉ាំរ៉ៃតែងតែទទួលបានការថែទាំ (៨១%)។ ប៉ុន្តែ ជិត ១៩% នៃករណីទាំងនេះ សមាជិកគ្រួសារគឺជាអ្នកមើលថែទាំ និងព្យាបាលដោយផ្ទាល់ ជំនួសអ្នកជំនាញថែទាំ។

ក្រាហ្វិចទី៤៣៖ តើមានសមាជិកគ្រួសារមានជំងឺរ៉ាំរ៉ៃឬទេ?




ក្រាហ្វិចទី៤៤៖ ប្រសិនបើមាន តើអ្នកមានទទួលបានសេវាកម្មថែទាំ ឬព្យាបាលឬទេ



មានតែអ្នកផ្តល់សម្ភាសចំនួនតែជិត ៤២% ប៉ុណ្ណោះ ដែលមានប័ណ្ណសមធម៌(សូមមើលក្រាហ្វិចទី៤៥)។ គួរតែមានការវិភាគបន្ថែមទៅលើប្រព័ន្ធនៃការផ្តល់ប័ណ្ណសមធម៌ ដើម្បីឈ្វេងយល់ថាតើការរកឃើញនេះស៊ីចង្វាក់គ្នានឹងកង្វះខាតនៃឯកសារសម្គាល់ផ្សេងទៀតដូចជាសៀវភៅគ្រួសារ ឬពាក់ព័ន្ធនឹងបញ្ហាផ្សេងទៀត។

ក្រាហ្វិចទី៤៥៖ តើគ្រួសាររបស់អ្នកទទួលបានប័ណ្ណសមធម៌ឬទេ?




ជាងពីរភាគបី (៦៤%) នៃអ្នកផ្តល់បទសម្ភាសបានបង្ហាញពីតម្រូវការឱ្យមានការវាយតម្លៃបន្ថែមក្នុងដំណើរការផ្តល់ប័ណ្ណសមធម៌។ អ្នកចូលរួមផ្តល់បទសម្ភាសជាច្រើនបានលើកឡើងថាពួកគេជឿថាគ្រួសារមួយចំនួនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានមើលរំលងដោយដំណើរការនេះ។ អ្នកចូលរួមផ្តល់បទសម្ភាសបានស្នើសុំឱ្យកំណត់រកគ្រួសារក្រីក្រទាំងអស់ ហើយការគាំទ្រគួរត្រូវបានផ្តល់ឱ្យចំគ្រួសារដែលក្រីក្រពិតប្រាកដ (សូមមើលក្រាហ្វិចទី៤៦)។

ក្រាហ្វិចទី៤៦៖ តាមការសង្កេតរបស់អ្នក តើគ្រួសារក្រីក្រទាំងអស់ទទួលបានប័ណ្ណសមធម៌ឬទេ




បំណុលក្នុងគ្រួសារ ក៏ជាបញ្ហាសំខាន់មួយផងដែរ នៅក្នុងសហគមន៍ក្រីក្រនៅទីក្រុង។ យ៉ាងហោចណាស់មានអ្នកចូលរួមផ្តល់បទសម្ភាសជាង ៦៩% មានជាប់ជំពាក់កម្ចីទាំងពីរគ្រឹះស្ថានផ្តល់ប្រាក់កម្ចី និងអ្នកផ្តល់កម្ចីឯកជន (សូមមើលក្រាហ្វិចទី ៤៧)។

ក្រាហ្វិចទី៤៧៖ បំណុលក្នុងគ្រួសារ




ជិត ៣០% នៃអ្នកចូលរួមផ្តល់បទសម្ភាសខ្ចីប្រាក់ដើម្បីធ្វើជាដើមទុនរកស៊ី ហើយជាង ២២% ទៀត យកប្រាក់កម្ចីដើម្បីសាងសង់ផ្ទះ។ គួរឱ្យព្រួយបារម្ភ ជាង ១៨% ប្រើប្រាស់ប្រាក់កម្ចីដើម្បីទិញចំណីអាហារ ហើយជាង ១១% ទៀត ប្រើប្រាស់ប្រាក់កម្ចី ដើម្បីចំណាយលើការព្យាបាលជំងឺ (សូមមើលតារាងទី៧)។ ការប្រើប្រាស់ប្រាក់កម្ចី ដើម្បីទិញម្ហូបអាហារ និងព្យាបាលជំងឺ គឺជាសញ្ញាមួយគួរឱ្យព្រួយបារម្ភ។ លើសពីនេះ នៅពេលសាកសួរអំពីលទ្ធភាពក្នុងការសងត្រឡប់វិញ ជាងពាក់កណ្តាលមានការពិបាកក្នុងការសងត្រឡប់ ហើយជិត ៥% បាននិយាយថាពួកគេមិនមានលទ្ធភាពសងនោះទេ (សូមមើលក្រាហ្វិចទី៤៨)។

### តារាងទី ៧៖ មូលហេតុនៃការខ្ចីប្រាក់

| ល.រ | បរិយាយ | ចំនួនមូលហេតុកម្ចី | % |
|---|---|---|---|
| ១ | ជាដើមទុនរកស៊ី | ៣១២ | ២៩.៦៦ |
| ២ | សាងសង់ផ្ទះ | ២៣២ | ២២.០៥ |
| ៣ | ទិញម្ហូប | ១៩១ | ១៨.១៦ |
| ៤ | សម្រាប់ថ្លៃព្យាបាលជំងឺ | ១១៨ | ១១.២២ |
| ៥ | ទិញសម្ភារៈក្នុងផ្ទះ | ១០៧ | ១០.១៧ |
| ៦ | បង់ថ្លៃសាលារៀនកូន | ២៩ | ២.៧៦ |
| ៧ | សម្រាលកូន | ១៤ | ១.៣៣ |
| ៨ | ទិញដី | ៩ | ០.៨៦ |
| ៩ | ទិញម៉ូតូ | ៧ | ០.៦៧ |
| ១០ | ជួសជុលផ្ទះ | ៧ | ០.៦៧ |
| ១១ | ការកូន | ៧ | ០.៦៧ |
| ១២ | ទិញរ៉ឺម៉ក | ៥ | ០.៤៨ |
| ១៣ | បង់រំលោះម៉ូតូ | ៤ | ០.៣៨ |
| ១៤ | សងបំណុល | ៤ | ០.៣៨ |
| ១៥ | កូនឈឺ | ១ | ០.១០ |
| ១៦ | ចាក់ដីនៅស្រុក | ១ | ០.១០ |
| ១៧ | បង់ថ្លៃជួលដីគេ | ១ | ០.១០ |
| ១៨ | ដោះស្រាយជីវភាពប្រចាំថ្ងៃ | ១ | ០.១០ |
| ១៩ | ទិញឡានជួលឱ្យគេ | ១ | ០.១០ |
| ២០ | ធ្វើបុណ្យសព | ១ | ០.១០ |
| សរុប | | ១០៥២ | ១០០% |

### ក្រាហ្វិចទី៤៨៖ លទ្ធភាពសងបំណុល



## ជ. អនាម័យ និងអនាម័យខ្លួនប្រាណ

ផ្នែកនេះនឹងពិនិត្យមើលទៅលើការអនុវត្តបច្ចុប្បន្នមួយចំនួនទាក់ទងនឹងអនាម័យ ដែលអាចមើលឃើញផ្ទាល់នឹងភ្នែក និងតាមទស្សនៈរបស់សហគមន៍ដែលចូលរួមក្នុងការសិក្សានេះ។ ការវាយតម្លៃនៅទីនេះនឹងផ្តោតទៅលើ បង្គន់អនាម័យក្នុងគ្រួសារ ការប្រើប្រាស់ទឹក និងស្ថានភាពទឹកជំនន់ដែលបានជួបប្រទះដោយសហគមន៍ដែលត្រូវបានជ្រើសរើសនៅក្នុងការសិក្សានេះ។

### បង្គន់អនាម័យ

ជិត ៩១% នៃអ្នកចូលរួមផ្តល់បទសម្ភាស បានលើកឡើងថាមានបង្គន់អនាម័យនៅក្នុងផ្ទះរបស់ពួកគេ។ ការរកឃើញនេះ បង្ហាញនូវការរីកចំរើនធំមួយលើបញ្ហាអនាម័យក្នុងគ្រួសារដែលពាក់ព័ន្ធជាមួយនឹងបញ្ហាបង្គន់អនាម័យក្នុងផ្ទះសហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ។

ក្រាហ្វិចទី៤៩៖ ចំនួនគ្រួសារដែលមានបង្គន់ក្នុងផ្ទះ




ក្រាហ្វិចទី៥០៖ ប្រភេទនៃបង្គន់នៅក្នុងផ្ទះ




គ្រួសារជាច្រើនដែលមិនមានបង្គន់អនាម័យនៅក្នុងផ្ទះ ប្រើប្រាស់បង្គន់អនាម័យរបស់អ្នកជិតខាង ឬបង្គន់សាធារណៈ។ ប៉ុន្តែគ្រួសារមួយចំនួន បន្តប្រើប្រាស់កន្លែងមិនមានអនាម័យ ធ្វើជាបង្គន់អនាម័យដូចជានៅលើផ្ទៃទឹក (ទន្លេ ឬបឹង) និងនៅតាមគុម្ពព្រៃក្បែរផ្ទះ (សូមមើលតារាងទី ៥១)។

ក្រាហ្វិចទី៥១៖ តើអ្នកបន្ទោរបង់នៅកន្លែងណា (សម្រាប់គ្រួសារដែលមិនមានបង្គន់អនាម័យ)?




### ទឹក

ការសិក្សាបានរកឃើញថា ទីតាំងលំនៅឋានភាគច្រើនទទួលបានទឹកស្អាតប្រើប្រាស់។ យ៉ាងហោចណាស់មានជាង ៨៧% នៃអ្នកចូលរួមផ្តល់បទសម្ភាសមានភ្ជាប់ប្រព័ន្ធទឹកស្អាតរបស់រដ្ឋសម្រាប់បរិភោគ ចម្អិនអាហារ និងលាងសម្អាត។ មានតែជាង ៥% ប៉ុណ្ណោះ ដែលនៅប្រើប្រាស់ទឹកអណ្តូងក្រោមដី និង ជាង ១% ប្រើប្រាស់ទឹកភ្លៀង (សូមមើលក្រាហ្វិចទី ៥២ និងក្រាហ្វិចទី ៥៣ ខាងក្រោម)។ ថ្វីត្បិតតែយ៉ាងនេះក្តី ការយល់ឃើញពីគុណភាពទឹកមានលក្ខណៈខុសៗគ្នា (សូមមើលក្រាហ្វិចទី ៥៤)។

ក្រាហ្វិចទី៥២៖ ប្រភពទឹកសម្រាប់បរិភោគ និងចម្អិនអាហារនៅក្នុងគ្រួសារ



ក្រាហ្វិចទី៥៣៖ ប្រភពទឹកសម្រាប់បោកគក់ និងងូត




ក្រាហ្វិចទី៥៤៖ ការយល់ឃើញពីគុណភាពទឹកដែលគ្រួសារប្រើប្រាស់




ប្រជាពលរដ្ឋក៏បានសម្តែងការយល់ដឹងអំពីសុវត្ថិភាពទឹកសម្រាប់បរិភោគផងដែរ។ ក្នុងចំណោមអ្នកចូលរួមផ្តល់បទសម្ភាសក្នុងការសិក្សានេះ ជាង ៥៥% ដាំទឹកមុននឹងបរិភោគ ជាង ៣០% ប្រើប្រាស់ទឹកសុទ្ធ និង ជិត ៨% បរិភោគទឹកពីធុងចម្រោះទឹកស្អាត។ មានតែ ជាង ៦% ប៉ុណ្ណោះដែលបរិភោគទឹកចេញភ្លាមៗពីប្រព័ន្ធទឹកស្អាតរបស់រដ្ឋ (សូមមើលក្រាហ្វិចទី៥៥)។

ក្រាហ្វិចទី៥៥៖ ទឹកសម្រាប់បរិភោគនៅក្នុងគ្រួសារ




## ទឹកជំនន់

ដូចនឹងអ្វីដែលបានរាយការណ៍ជាទូទៅ ជាពិសេសក្នុងរដូវភ្លៀង មានតំបន់លំនៅឋានជាច្រើននៅរាជធានីភ្នំពេញជន់លិច។ ទឹកជន់ខ្លះមានរយៈពេលដល់ទៅច្រើនម៉ោង ខណៈដែលខ្លះទៀតអាចឈានដល់រាប់ខែ។ ដោយសារការសិក្សានេះត្រូវបានធ្វើឡើងនៅចំរដូវភ្លៀង បទពិសោធន៍ជាក់ស្តែងមួយចំនួនត្រូវបានជួបប្រទះក្នុងអំឡុងពេលនៃការចុះស្ទង់មតិនេះ។ ជិតពាក់កណ្តាល (៤៤%) នៃអ្នកចូលរួមផ្តល់បទសម្ភាសកំពុងជួបប្រទះនឹងទឹកជំនន់ជាប្រចាំនៅក្នុងសហគមន៍របស់ពួកគេ។ ក្នុងចំណោមអ្នកទាំងនោះជិត ២៨% បានពន្យល់ប្រាប់ថាទឹកជំនន់ស្រកចុះភ្លាមៗ ក្រោយពេលមេឃរាំងភ្លៀង។ ជិត១៧% ផ្សេងទៀតបាននិយាយថាទឹកនៅតែជន់ស្ទើរតែមួយសប្តាហ៍ ជិត ១៥% ទៀតបានប្រាប់ថាទឹកនៅជន់រយៈពេលពី ១ សប្តាហ៍ ទៅ ១ខែ។ គួរឱ្យភ្ញាក់ផ្អើលមួយទៀតនោះគឺមានជិត ៤១% នៃអ្នកចូលរួមផ្តល់បទសម្ភាសដែលជួបនឹងបញ្ហាទឹកជំនន់ជាប្រចាំនេះ បាននិយាយថាទឹកជន់បន្តនៅមានរយៈពេលលើសពីមួយខែ។ ជាការកត់សម្គាល់សហគមន៍មួយចំនួននៅក្នុងការសិក្សានេះរស់នៅលើដីបឹងឬតំបន់ដីទាបនៅក្នុងរាជធានីភ្នំពេញ។

ក្រាហ្វិចទី៥៦៖ ស្ថានភាពទឹកជំនន់ចំពោះផ្ទះសម្បែងរបស់គ្រួសារ




ក្រាហ្វិចទី៥៧៖ តើផ្ទះសម្បែងលិចទឹករយៈពេលយូរប៉ុនណានៅពេលមានទឹកជន់ម្តង?



ខណៈដែលមានការពិភាក្សាអំពីទឹកជំនន់ ក្រុមអ្នកស្រាវជ្រាវក៏បានព្យាយាមស្តាប់ពីទស្សនៈរបស់អ្នកចូលរួមផ្តល់បទសម្ភាសអំពីសមត្ថភាពរបស់អាជ្ញាធរក្នុងការដោះស្រាយបញ្ហាទឹកជំនន់នេះផងដែរ។ ជាង ១២% ប៉ុណ្ណោះពេញចិត្តនឹងដំណោះស្រាយរបស់អាជ្ញាធររាជរដ្ឋាភិបាល រីឯ ជាង ៣៨% មិនពេញចិត្តនោះទេ។ ស្ទើរតែពាក់កណ្តាល (៤៩%) នៃអ្នកចូលរួមផ្តល់បទសម្ភាសបានបដិសេដមិនបញ្ចេញយោបល់ (សូមមើលក្រាហ្វិចទី ៥៨)។

ក្រាហ្វិចទី៥៨៖ ការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលក្នុងអំឡុងពេលមានទឹកជំនន់





## ឈ. ទ្រព្យសម្បត្តិរបស់ក្រុមគ្រួសារ

ការវាយតម្លៃអំពីទ្រព្យសម្បត្តិ របស់ក្រុមគ្រួសារក៏ត្រូវបានធ្វើឡើង ដោយពិនិត្យមើលជាពិសេសលើមធ្យោបាយធ្វើដំណើរក្នុងក្រុមគ្រួសារ និងសម្ភារៈដែលក្រុមគ្រួសារប្រើប្រាស់សម្រាប់ទំនាក់ទំនង (សម្ភារៈ និងឧបករណ៍ទំនាក់ទំនង)។ ជិតពីរភាគបី (ជិត ៦៩%) នៃអ្នកចូលរួមផ្តល់បទសម្ភាសមានម៉ូតូមួយគ្រឿង។ គួរឱ្យចាប់អារម្មណ៍នោះ ប្រមាណ 0,0៦% នៃប្រជាពលរដ្ឋនៅក្នុងការសិក្សានេះបានអះអាងថាគ្មានមធ្យោបាយធ្វើដំណើរនៅក្នុងគ្រួសារ។ អ្នកទាំងនេះពឹងផ្អែកទាំងស្រុងលើមធ្យោបាយធ្វើដំណើរសាធារណៈ ឬដោយថ្មើរជើងសម្រាប់ចម្ងាយជិត (សូមមើលតារាងទី ៥៩)។

ក្រាហ្វិចទី៥៩៖ មធ្យោបាយធ្វើដំណើរសម្រាប់ក្រុមគ្រួសារ




សម្រាប់ការទំនាក់ទំនងវិញ ជាង ៦៦% មានទូរស័ព្ទស្មាតហ្វូន ហើយ ជាង ១៥% ប្រើប្រភេទទូរស័ព្ទដៃផ្សេងទៀត។ ជាង ១៥ មានទូរទស្សន៍ ហើយ ជាង ២% មានវិទ្យុ (សូមមើលតារាងទី៦0)។

ក្រាហ្វិចទី៦0៖ សម្ភារៈ ឬឧបករណ៍សម្រាប់ការទំនាក់ទំនង



## ៣. លទ្ធភាពទទួលបានអគ្គិសនីរបស់សហគមន៍

មានភាពប្រសើរល្អមួយនូវលទ្ធភាព ទទួលបានអគ្គិសនីរបស់សហគមន៍ក្រីក្រនៅក្នុងទីក្រុង។ គ្រួសារស្ទើរតែទាំងអស់នៅក្នុងការសិក្សានេះមានអគ្គិសនីរដ្ឋប្រើប្រាស់។ ក្នុងចំណោមនោះ ជិត ៨៧% បានតភ្ជាប់អគ្គិសនីរដ្ឋផ្ទាល់ ខណៈដែលជាង ១១% បានតភ្ជាប់តាមរយៈអ្នកជិតខាង។ គ្រួសារដែលនៅសល់ដទៃទៀតនៅប្រើប្រាស់អាគុយ ឬពឹងផ្អែកលើថាមពលពន្លឺព្រះអាទិត្យ (សូមមើលក្រាហ្វិចទី ៦១)។

ក្រាហ្វិចទី៦១៖ អគ្គិសនីក្នុងផ្ទះសម្បែង




## ង. ថាមពលសម្រាប់ចម្អិនអាហារ

ដូចដែលការសិក្សានេះបង្ហាញឱ្យដឹង អ្នកចូលរួមផ្តល់បទសម្ភាសភាគច្រើន ជាង ៥៧% ប្រើប្រាស់ឧស្ម័នហ្គាសសម្រាប់ចម្អិនអាហារ។ យ៉ាងហោចណាស់ ជាង ៩% នៃអ្នកចូលរួមក្នុងការសិក្សានេះនៅពឹងផ្អែកលើអុសដើម្បីចម្អិនអាហារ (សូមមើលក្រាហ្វិចទី ៦២)។

ក្រាហ្វិចទី៦២៖ ការប្រើប្រាស់ថាមពលសម្រាប់ចម្អិនអាហារក្នុងគ្រួសារ



# ៩. សេចក្តីសន្និដ្ឋាន

ផ្អែកតាមលទ្ធផលនៃការវាយតម្លៃនេះ សហគមន៍ក្រីក្រនៅរាជធានីភ្នំពេញ មានអគ្គិសនីរដ្ឋប្រើប្រាស់ ហើយគ្រួសារស្ទើរតែទាំងអស់បានតភ្ជាប់ប្រព័ន្ធទឹកស្អាតរបស់រដ្ឋ។ សហគមន៍ក៏មានលទ្ធភាពទទួលបានសេវាថែទាំសុខភាព និងការអប់រំ។

ទោះជាយ៉ាងនេះក្តី សហគមន៍ក្រីក្រនៅក្នុងទីក្រុងនៅតែជួបប្រទះនឹងបញ្ហាជាច្រើនដែលតម្រូវឱ្យមានដំណោះស្រាយ និងការជួយជ្រោមជ្រែង។ ស្ថានភាពភូមិសាស្ត្រដែលមានគ្រួសាររស់នៅតាមបណ្តោយផ្លូវ ប្រឡាយទឹកស្អុយ ផ្លូវរថភ្លើង មាត់ទន្លេ និងបឹង បង្ហាញថាសហគមន៍ទាំងនេះប្រឈមនឹងហានិភ័យខ្ពស់នៃការបណ្តេញចេញ។

ទឹកជំនន់ជាបញ្ហាដែលមានសភាពធ្ងន់ធ្ងរចំពោះសហគមន៍ក្រីក្រនៅក្នុងទីក្រុងជាច្រើន ជាពិសេសតំបន់ដែលមានហេដ្ឋារចនាសម្ព័ន្ធមិនទាន់គ្រប់គ្រាន់ រួមមានផ្លូវ ប្រឡាយបង្ហូរទឹក និងកង្វះប្រព័ន្ធលូទឹកស្អុយ។ សហគមន៍ដែលរស់នៅលើបឹង និងតំបន់ដីសើមដែលកំពុងតែត្រូវបានគេចាក់បំពេញ ក៏ប្រឈមនឹងហានិភ័យកាន់តែច្រើនផងដែរ។

ភាពក្រីក្រក៏ជាកត្តាគួរឱ្យព្រួយបារម្ភមួយដែរ ខណៈជំងឺកូវីដ-១៩ បាននិងកំពុងធ្វើឱ្យប៉ះពាល់ដល់ប្រាក់ចំណូលរបស់ពួកគេ។ កម្ចីត្រូវបានយកដើម្បីទិញចំណីអាហារ និងថ្នាំពេទ្យ ហើយអ្នកចូលរួមផ្តល់បទសម្ភាសដែលត្រូវបានសម្ភាសក្នុងការស្រាវជ្រាវនេះបាននិយាយប្រាប់ថាកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅមិនទាន់អនុវត្តបានត្រឹមត្រូវនៅឡើយ។ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនេះ ប្រសិនបើ អនុវត្តបានត្រឹមត្រូវ អាចជួយកាត់បន្ថយការចំណាយលើថ្លៃព្យាបាល និងការផ្តល់នូវសេវាកម្មចាំបាច់ដល់សមាជិកសហគមន៍ក្រីក្រនៅក្នុងទីក្រុង។

# ១០. អនុសាសន៍

## ១. តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល

### សមត្ថភាពក្នុងការតស៊ូមតិ

- ដូចដែលបានរកឃើញក្នុងការសិក្សានេះ សហគមន៍ដែលរស់នៅក្បែរដីរបស់រដ្ឋអាចនឹងត្រូវបានគេបណ្តេញចេញដោយបង្ខំឱ្យផ្លាស់ទីលំនៅដើម្បីការអភិវឌ្ឍទីក្រុង។ ដូចនេះ អង្គការមិនមែនរដ្ឋាភិបាលអាចមានតួនាទីយ៉ាងសំខាន់ ក្នុងការជួយឱ្យសហគមន៍ទទួលបានព័ត៌មាន អំពីគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល នីតិវិធី និងតម្រូវការផ្នែកច្បាប់នានាដើម្បីធានាថាការអនុវត្តជាក់ស្តែងមានតម្លាភាព និងគណនេយ្យភាព។
- ការពិគ្រោះយោបល់ និងការប្រជុំជាទៀងទាត់រវាងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការជាមួយសហគមន៍ក្រីក្រនៅទីក្រុងនៅតែមានសារៈសំខាន់យ៉ាងខ្លាំង និងគួរត្រូវបានអនុវត្តបន្តទៀតដើម្បីផ្លាស់ប្តូរព័ត៌មាន ការគាំទ្រ ព្រមទាំងការសកម្មភាពរួមគ្នាតាមការចាំបាច់។
- ការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលក្នុងការកសាងសមត្ថភាពបន្ថែមទៀតរបស់បណ្តាញសហគមន៍ ដូចមាននៅក្នុងអនុសាសន៍ទី ៥ខាងលើ។
- ដោយសារនៅក្នុងសិក្សារកឃើញថា បំណុលភាគច្រើនពាក់ព័ន្ធនឹងការជួយដល់អាជីវកម្មខ្នាតតូច ដូច្នេះអង្គការក្រៅរដ្ឋាភិបាលគួរធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកជំនាញលើសហគ្រាសសង្គម និងការអភិវឌ្ឍន៍សហគ្រិនភាព។

## ២. ការរួមបញ្ចូលប្រព័ន្ធផ្សព្វផ្សាយក្នុងការតស៊ូមតិ

- តួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅតែមានសារៈសំខាន់សម្រាប់ឱ្យប្រជាពលរដ្ឋ និងសហគមន៍ សម្តែងពីក្តីបារម្ភ និងបញ្ហា ពីក្នុងសហគមន៍ទៅកាន់សាធារណៈជន។ ក្នុងករណីនេះ អ្នកដឹកនាំសហគមន៍យល់ដឹងអំពីប្រព័ន្ធផ្សព្វផ្សាយ និងស្ថាប័នសារព័ត៌មានឯករាជ្យទាំងអស់ ហើយធ្វើការទាក់ទង ជាមួយពួកគេដើម្បីធ្វើការសម្ភាសនៅពេលចាំបាច់។

## ៣. រាជរដ្ឋាភិបាល ឬសាលារាជធានីភ្នំពេញ

- ការបណ្តេញចេញដោយបង្ខំជារឿយៗមានពាក់ព័ន្ធនឹងសំណងហិរញ្ញវត្ថុមួយចំនួន ឬការតាំងទីលំនៅថ្មី។ ការសង្កេតជាច្រើនបានបង្ហាញឱ្យដឹងថាដំណើរការទាំងនេះជាទូទៅធ្វើឡើងដោយគ្មានការពិភាក្សាជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ ផ្ទុយទៅវិញតែងតែធ្វើឡើងតាមរយៈការគំរាមកំហែងមិនផ្តល់សំណងអ្វីទាំងអស់ ជាជាងការចរចារ និងពិគ្រោះយោបល់ជាមួយសហគមន៍ប្រកបដោយតម្លាភាព និងអភិបាលកិច្ចល្អ។ ការពិគ្រោះយោបល់រវាងសហគមន៍ និងស្ថាប័នរាជរដ្ឋាភិបាលអំពីសំណង និងការតាំងទីលំនៅថ្មី គឺជាអនុសាសន៍មួយ ដើម្បីធានាថាជីវភាពរបស់គ្រួសារដែលរងផលប៉ះពាល់នឹងមិនរងផលលំបាកកាន់តែខ្លាំងដែលនាំឱ្យពួកគេកាន់តែជំពាក់បំណុល និងធ្លាក់ក្នុងភាពក្រីក្រកាន់តែខ្លាំង។
- ដូចបានឈ្វេងយល់តាមរយៈការសិក្សានេះ សហគមន៍ក្រីក្រនៅក្នុងទីក្រុងជាច្រើនកំពុងជួបប្រទះនឹងបញ្ហាទឹកជំនន់ធ្ងន់ធ្ងរ។ ផ្ទះសម្បែងខ្លះលិចទឹកជាច្រើនខែ ជាពិសេសក្នុងរដូវភ្លៀង។ ក្នុងករណីនេះ បញ្ហាមួយនេះគួរតែដោះស្រាយដោយរាជរដ្ឋាភិបាល ឬសាលារាជធានីភ្នំពេញ។

# ១១. ឧបសម្ព័ន្ធ

## បញ្ជីសំណួរសំរាប់ធ្វើការប៉ាន់ប្រមាណលើជីវភាពរស់នៅ របស់ពលរដ្ឋក្នុងសហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ

សូមគោរពលោក លោកស្រី អ្នកនាង កញ្ញា

ការស្រាវជ្រាវនេះមានគោលបំណងដើម្បីស្វែងយល់និងប៉ាន់ប្រម៉ាណលើស្ថានភាពបច្ចុប្បន្ននៃជីវភាពរស់នៅរបស់គ្រួសារដែលកំពុងរស់នៅក្នុងសហគមន៍នានា ក្នុងតំបន់ជាយក្រុង ឬក្នុងទីក្រុងភ្នំពេញ។ លទ្ធផលរបស់របាយការណ៍នេះនឹងត្រូវយកមកធ្វើជាសេចក្តីព្រៀងគំនិត និងអនុសាសន៍ ដើម្បីកែលម្អស្ថានភាព និងជីវភាពរស់នៅរបស់អ្នកភូមិ ក្នុងគោលបំណងជួយអោយពលរដ្ឋដែលកំពុងរស់នៅក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង ទទួលបាននូវការអភិវឌ្ឍប្រកបដោយភាពគំនិតផ្តួចផ្តើមដោយខ្លួនឯង និងមាននិរន្តរភាព។

ដើម្បីអោយអាចទទួលបាននូវលទ្ធផលដូចបានរំពឹងទុកខាងលើ យើងសូមសួរអ្នកនូវសំនួរមួយចំនួនដែលត្រូវចំណាយពេលប្រហែលមួយម៉ោង។ យើងមានការកោតសរសើរយ៉ាងក្រៃលែងសំរាប់ការចូលរួមរបស់អ្នកក្នុងការសម្ភាសន៍នៅពេលនេះ។

យើងនឹងរក្សារាល់ការសម្ងាត់នូវព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកដូចជាឈ្មោះលោកអ្នកនិងឈ្មោះសមាជិកគ្រួសារ។ព័ត៌មានរបស់អ្នកនឹងមិនត្រូវបង្ហាញទៅអ្នកដ៏ទៃផ្សេងទៀតឡើយ។ យើងសូមអគុណយ៉ាងជ្រាលជ្រៅ ចំពោះការស្ម័គ្រចិត្តរបស់អ្នក។ យើងជឿជាក់ថាមតិរបស់អ្នកនឹងផ្តល់អោយយើងនូវព័ត៌មានដ៏មានតម្លៃ។ ការស្រាវជ្រាវនេះ ជាផ្នែកមួយនៃគម្រោងការអភិវឌ្ឍដែលផ្តួចផ្តើមឡើងដោយអង្គការសមាគមធាងត្នោត(STT) ហើយនឹងត្រូវបានប្រើជាទិន្នន័យមូលដ្ឋានគ្រឹះសម្រាប់ការជួយធ្វើអោយបានប្រសើរឡើង ដល់ជីវភាពរស់នៅរបស់ពលរដ្ឋនៅក្នុងតំបន់ក្រីក្រក្នុងទីក្រុងភ្នំពេញ។

ប្រសិនបើអ្នកមានសំនួរណាមួយ ដែលទាក់ទងនិងការស្ទង់មតិនេះ សូមទំនាក់ទំនងទៅតាមលេខទូរស័ព្ទ ខាងក្រោមនេះ
អង្គការសមាគមធាងត្នោត:……………………………………………………………………………………

សូមអគុណចំពោះការចូលរួមរបស់លោក លោកស្រី អ្នកនាង កញ្ញា។

លេខកូដ___________________
កាលបរិច្ឆេទ_______/________/___________
ពេលចាប់ផ្តើម:______________________          ពេលបញ្ចប់ :________________________
ឈ្មោះមន្ត្រីសម្ភាសន៍: ________________________________________________________
ទីកន្លែងសម្ភាសន៍: សហគមន៍:_______  ភូមិ:________  សង្កាត់: ________  ស្រុក: ________

## ១. ព័ត៌មានផ្ទាល់ខ្លួន

(ក្នុងខណៈពេលដែលមេគ្រួសារអវត្តមានមិនបានចូលរួមនៅពេលសម្ភាសន៍ យើងអាចរើសមនុស្សថ្មីមកជំនួសបានពីក្នុងគ្រួសារនេះបាន ប៉ុន្តែត្រូវមានអាយុពី១៨ឆ្នាំឡើងទៅ)

១.១. ឈ្មោះ_________________លេខទូរស័ព្ទ _______________
១.២. អាយុ__________________ឆ្នាំ        ភេទ:     ១. ប្រុស  ២. ស្រី
១.៣. ស្ថានភាពគ្រួសារ

- មិនទាន់រៀបការ
- មានគ្រួសារ
- ស្នាក់នៅផ្សេងគ្នា
- លែងលះ
- ពោះម៉ាយ

១.៤. ទំនាក់ទំនងរបស់អ្នកនៅក្នុងគ្រួសារនេះ៖

- មេគ្រួសារ
- ប្តី/ប្រពន្ធ
- បងប្រុសឬស្រី
- កូនប្រុសស្រី
- កូនប្រសារ
- ចៅ
- អាណាព្យាបាល
- ទំនាក់ទំនងផ្សេងទៀត

១.៥. មុខរបរបច្ចុប្បន្ន៖ ...........................................
១.៦. សញ្ជាតិ

- ខ្មែរ
- ចិន
- ខ្មែរអីស្លាម
- វៀតណាម
- សញ្ជាតិដទៃទៀត_______

១.៧. សាសនា៖

- ព្រះពុទ្ធ
- គ្រឹស្ត
- មូសស្លីម
- បាហាយ
- សាសនាដទៃទៀត សូមបញ្ជាក់_____

១.៨. កំរិតវប្បធម៌៖

- គ្មាន
- ថ្នាក់ទី១
- ថ្នាក់ទី២
- ថ្នាក់ទី៣
- ថ្នាក់ទី៤
- ថ្នាក់ទី៥
- ថ្នាក់ទី៦
- ថ្នាក់ទី៧
- ថ្នាក់ទី៨
- ថ្នាក់ទី៩
- ថ្នាក់ទី១០
- ថ្នាក់ទី១១
- ថ្នាក់ទី១២
- សកលឆ្នាំទី១
- សកលឆ្នាំទី២
- សកលឆ្នាំទី៣
- សកលឆ្នាំទី៤
- បញ្ចប់សកលវិទ្យាល័យ
- ផ្សេងៗ_____

១.៩. តើអ្នកចូលមករស់នៅក្នុងសហគមន៍នេះពីពេលណា?

- ទើបមករស់នៅជិតមួយឆ្នាំ
- ពី១ឆ្នាំដល់២ឆ្នាំ
- ២ទៅ៣ឆ្នាំ
- ៤ទៅ៥ឆ្នាំ
- ៦ទៅ១០ឆ្នាំ
- លើសពី១០ឆ្នាំ
- ខ្ញុំកើតនៅទីនេះ

## ២. ស្ថានភាពសេដ្ឋកិច្ចនិងសង្គមរបស់គ្រួសារ

| ល.រ | សំនួរ | សរុប | ស្រី |
|---|---|---|---|
| ២.១ | នៅក្នុងផ្ទះនេះមានសមាជិកគ្រួសារប៉ុន្មាននាក់? | | |
| ២.២ | មានសមាជិកប៉ុន្មាននាក់ដែលមានអាយុក្រោម១៨ឆ្នាំ? | | |
| ២.៣ | នៅមុនការផ្ទុះជម្ងឺកូវីតតើមានសមាជិកគ្រួសារប៉ុន្មាននាក់ដែលជាអ្នករកប្រាក់ចំណូលសំរាប់ជួយគ្រួសារនេះ? | | |

| | | | |
|---|---|---|---|
| ២.៤ | តើនរណាខ្លះជានាក់រកប្រាក់ចំណូលនៅក្នុងគ្រួសារនេះ?<br>ប្ដី<br>ប្រពន្ធ<br>អ្នកម៉េម៉ាយ<br>កូន<br>ចៅប្រុស ស្រី<br>អ្នកដ៏ទៃទៀត,សូមបញ្ជាក់<br>........................ | (ចំ.អាចលើសពី មួយ)<br>១<br>២<br>៣<br>៤<br>៥<br>៦ | |
| ២.៥ | នៅក្នុងអំឡុងពេលនេះមានសមាជិកគ្រួសារ ដែលត្រូវបាត់បង់ការងារដោយសារតែវិបត្តិជម្ងឺកូវីតដែរឬទេ?<br>មាន<br>គ្មានទេ | <br><br>១<br>២(រំលងសំនួរ 2.6) | |
| ២.៦ | បើមានតើប៉ុន្មាននាក់ហើយដែលត្រូវបានបាត់បង់ការងារដោយសារកូវីត? | | |
| ២.៧ | កំរិតប្រាក់ចំណូលប្រចាំខែសំរាប់គ្រួសារមុនពេលផ្ទុះជម្ងឺកូវីត?<br><br>គ្មានចំណូល<br>តិចជាង ១០០, ០០០ រៀល<br>ចន្លោះ ១០០,០០០ ពី ២០០,០០០ រៀល<br>ចន្លោះ ២០០,០០០ ពី ៣០០,០០០ រៀល<br>ចន្លោះ ៣០០,០០០ ពី ៤០០,០០០ រៀល<br>ចន្លោះ ៤០០,០០០ ពី ៥០០,០០០រៀល<br>ចន្លោះ ៥០០,០០០ ពី ៦០០,០០០រៀល<br>ចន្លោះ ៦០០,០០០ ពី ៧០០,០០០ រៀល<br>ចន្លោះ ៧០០,០០០ ពី ៨០០,០០០ រៀល<br>ចន្លោះ ៨០០,០០០ ពី ១,០០០,០០០ រៀល<br>ចន្លោះ ១,០០០,០០០ ពី ២,០០០,០០០ រៀល<br>ច្រើនជាង ២,០០០,០០០ រៀល | <br><br>១<br>២<br>៣<br>៤<br>៥<br>៦<br>៧<br>៨<br>៩<br>១០<br>១១<br>១២ | |
| ២.៨ | តើជម្ងឺកូវីតមានផ្តល់ផលប៉ះពាល់ដល់ប្រាក់ចំណូលរបស់គ្រួសារអ្នកដែរឬទេ?<br>មាន<br>គ្មានការប្រែប្រួលទេ | ១<br>២<br>(បើគ្មាន ត្រូវរំលងសំនួរ ២.៩) | |

| | | | |
|---|---|---|---|
| ២.៩ | ប្រសិនបើមាន តើធ្លាក់ចុះដល់កំរិតណាក្នុងមួយខែ?<br>គ្មានចំណូល<br>តិចជាង ១០០, ០០០ រៀល<br>ចន្លោះ ១០០,០០០ ពី ២០០,០០០ រៀល<br>ចន្លោះ ២០០,០០០ ពី ៣០០,០០០ រៀល<br>ចន្លោះ ៣០០,០០០ ពី ៤០០,០០០ រៀល<br>ចន្លោះ ៤០០,០០០ ពី ៥០០,០០០រៀល<br>ចន្លោះ ៥០០,០០០ ពី ៦០០,០០០រៀល<br>ចន្លោះ ៦០០,០០០ ពី ៧០០,០០០ រៀល<br>ចន្លោះ ៧០០,០០០ ពី ៨០០,០០០ រៀល<br>ចន្លោះ ៨០០,០០០ ពី ១,០០០,០០០ រៀល<br>ចន្លោះ ១,០០០,០០០ ពី ២,០០០,០០០ រៀល<br>ច្រើនជាង ២,០០០,០០០ រៀល | <br>១<br>២<br>៣<br>៤<br>៥<br>៦<br>៧<br>៨<br>៩<br>១០<br>១១<br>១២ | |
| ២.១០ | ប្រភពប្រាក់ចំណូលធំៗពីមុខរបរក្នុង គ្រួសាររបស់អ្នក?សូមជ្រើសរើស<br>កម្មកររោងចក្រ<br>កម្មករសំណង់<br>ម៉ូតូឌុប<br>លក់ដូរក្នុងភូមិ<br>មន្ត្រីរាជការ<br>បុគ្គលិកក្រុមហ៊ុន<br>បុគ្គលិកអង្គការ<br>របរកសិកម្ម<br>សិប្បកម្ម<br>រើសអេតចាយ<br>សេវាកម្មកំសាន្ត<br>សេវាកម្មបោកអ៊ុត<br>របរផ្សេងទៀត,សូមបញ្ជាក់<br>..................... | (ចំលើយ អាចលើស ពីមួយ)<br>១<br>២<br>៣<br>៤<br>៥<br>៦<br>៧<br>៨<br>៩<br>១០<br>១១<br>១២<br>១៣ | |

| | | | |
|---|---|---|---|
| ២.១១ | ស្ថានភាពទីតាំងដែលគ្រួសារអ្នកកំពុងរស់នៅ?<br>នៅតាមបណ្តោយផ្លូវរថភ្លើង<br>តាមបណ្តោយផ្លូវសាធារណៈ<br>តាមបណ្តោយលូទឹកស្អុយ<br>តាមបណ្តោយច្រាំងដងទន្លេ<br>ផ្ទះលើទឹកដងទន្លេ<br>លើដីគេចែកអោយ<br>លើដីរបស់រដ្ឋ<br>នៅក្រោមដំបូលអាគារ<br>នៅក្នុងវត្ត/ចេតិយ<br>លើទឹកបឹង<br>លើដីជាកម្មសិទ្ធអ្នកដ៏ទៃ<br>ផ្សេងទៀត, សូមបញ្ជាក់ ........................ | <br>១<br>២<br>៣<br>៤<br>៥<br>៦<br>៧<br>៨<br>៩<br>១០<br>១១<br>១២ | |
| ២.១២ | តើក្នុងរយៈពេល៥ឆ្នាំកន្លងទៅគ្រួសាររបស់អ្នកមានបានរុះរើទីលំនៅដែរឬទេ?<br>បាទមាន<br>មិនមានទេ | <br><br>១<br>២ (បើទេ សូមចូលទៅចំណុចទី ៣) | |
| ២.១៣ | ប្រសិនបើមានតើប៉ុន្មានដងក្នុង៥ឆ្នាំចុងក្រោយ?<br>តែម្តងគត់<br>២ដង<br>៣ដង<br>លើសពី៣ដង | <br>១<br>២<br>៣<br>៤ | |
| ២.១៤ | មូលហេតុនៃការរុះរើ?(មូលហេតុសំខាន់ចុងក្រោយ)<br>ដោយសារតែសេដ្ឋកិច្ច<br>ចង់ប្តូរទៅកន្លែងថ្មី<br>ទៅនៅជិតបងប្អូនឬឪពុកម្តាយ<br>ត្រូវអាជ្ញាធរបង្ខំអោយចាកចេញ<br>ផ្សេងៗ<br>…………………………………… | <br>១<br>២<br>៣<br>៤<br>៥ | |

## ៣. ស្ថានភាពលំនៅដ្ឋាន

| | | |
|---|---|---|
| ៣.១ | ទំនាក់ទំនងជាមួយលំនៅដ្ឋានបច្ចុប្បន្ន?<br>ជាកម្មសិទ្ធផ្ទាល់ខ្លួន<br>ជាផ្ទះជួល<br>ស្នាក់នៅជាមួយមិត្តភក្តិឬបងប្អូន<br>ផ្សេងទៀតសូមបញ្ជាក់......................... | <br>១<br>២ (សូមរំលងសំនួរ ៣.២)<br>៣ (សូមរំលងសំនួរ ៣.២)<br>៤ |
| ៣.២ | តើអ្នកបានប្រភពប្រាក់មកពីណាក្នុងការសាងសង់លំនៅដ្ឋាននេះ?<br>ប្រាក់ផ្ទាល់ខ្លួន<br>ខ្ចីសាច់ញាតិឬបងប្អូន<br>ខ្ចីធនាគារ<br>ផ្សេងៗ<br>……………………………………… | <br>១<br>២<br>៣<br>៤ |
| ៣.៣ | ប្រភេទផ្ទះដែលគ្រួសារកំពុងរស់នៅ?(សូមជ្រើសរើស)<br>ជាលំនៅបណ្តោះអាសន្នក្រោមតង់កៅស៊ូ<br>សង់ពីឈើតូចៗដំបូលស្លឹក ឬស្បូវ ឬប្រក់<br>ក្រណាត់<br>សង់ពីឈើតូចៗប្រក់ស័ង្កសី<br>សំណង់សមរម្យធម្មតា<br>សំណង់រឹងមាំសង់ពីថ្ម<br>ផ្សេងទៀតសូមបញ្ជាក់<br>............................ | <br>១<br>២<br>៣<br>៤<br>៥<br>៦<br>៧ |
| ៣.៤ | ស្ថានភាពរស់នៅក្នុងលំនៅដ្ឋាន?<br>ល្មមសមរម្យ<br>ចង្អៀតបន្តិច<br>ចង្អៀតខ្លាំង | <br>១<br>២<br>៣ |
| ៣.៥ | តើអ្នកយល់យ៉ាងណាពីស្ថេរភាពនៃសហគមន៍របស់អ្នក? | |

## ៤. ព័ត៌មានសំរាប់ឯកសារប្រចាំគ្រួសារ

| | | |
|---|---|---|
| ៤.១ | តើគ្រួសារអ្នកមានសៀវភៅគ្រួសារដែរឬទេ?<br>មាន<br>មិនមានទេ | <br>១(បើមាន សូមរំលងសំនួរ ៤.២)<br>២ |

| | | |
|---|---|---|
| ៤.២ | បើគ្មានហេតុអ្វី?<br>មិនបានធ្វើ<br>ធ្វើហើយតែបាត់<br>ធ្វើហើយតែខូច<br>ធ្វើហើយតែមិនទាន់បានទទួល<br>ជាប់បញ្ហាដើម្បីខ្ចីប្រាក់គេ<br>ផ្សេងៗ<br>............................................ | ១<br>២<br>៣<br>៤<br>៥ |
| ៤.៣ | តើគ្រួសារអ្នកមានសៀវភៅស្នាក់នៅដែរឬទេ?<br>មាន<br>គ្មានទេ | ១(បើមាន សូមរំលងសំនួរ 4.4)<br>២ |

## ៥. សេវាកម្មថែទាំសុខភាព

| | | |
|---|---|---|
| ៥.១ | ចំនួនក្មេងអាយុក្រោម១២ខែនៅក្នុងបន្ទុក?<br>មាន<br>គ្មានទេ | ១<br>២ (បើគ្មាន សូមរំលងសំនួរ ៥.២ & ៥.៣) |
| ៥.២ | តើក្មេងក្នុងបន្ទុកគ្រួសារបានទទួលការចាក់វ៉ាក់សាំងគ្រប់គ្នាដែរឬទេ?<br>បានគ្រប់គ្នា<br>បានខ្លះ<br>មិនមាននរណាបានចាក់ទេ<br>មិនច្បាស់ | ១<br>២<br>៣<br>៤ |
| ៥.៣ | តើក្មេងអាយុក្រោម ១២ខែមានសៀវភៅតាមដានសុខភាពកុមារឬទេ?<br>មាន<br>មានតែបាត់<br>គ្មាន | ១<br>២<br>៣ |
| ៥.៤ | នៅក្នុងគ្រួសារនេះមានស្ត្រីមានផ្ទៃពោះដែរឬទេ?<br>មាន<br>គ្មានទេ | ១<br>២ (បើគ្មានសូមរំលងសំនួរ ៥.៥ & ៥.៦) |

| | | |
|---|---|---|
| ៥.៥ | បើមានតើគាត់បានទៅទទួលការថែទាំសុខភាពពេលមានផ្ទៃពោះដែរឬទេ?<br>ទៅដោយទៀងទាត់<br>ទៅញឹកញាប់<br>ទៅម្តងម្កាល<br>មិនដែលទៅទេ | <br>១<br>២<br>៣<br>៤ (បើទេ សូមរំលងសំនួរ ៥.៦ & ៥.៧) |
| ៥.៦ | បើបានទទួលតើគាត់ទទួលពីកន្លែងណា?<br>មណ្ឌលសុខភាព<br>មន្ទីរពេទ្យរដ្ឋ<br>គ្លីនិកឯកជន<br>ពីសំណាក់ឆ្មបបុរាណ<br>សេវាកម្មផ្តល់ដោយNGO<br>កន្លែងផ្សេងទៀត .................................. | <br>១<br>២<br>៣<br>៤<br>៥<br>៦ |
| ៥.៧ | តើគាត់ធ្វើដំណើរទៅកន្លែងពិនិត្យសុខភាពដោយរបៀបណា?<br>ដោយមធ្យោបាយផ្ទាល់ខ្លួន<br>តាមរយៈជំនួយពីអង្គការ<br>តាមរយៈជំនួយពីអាជ្ញាធរមូលដ្ឋាន<br>ផ្សេងទៀត........................................ | <br>១<br>២<br>៣<br>៤ |
| ៥.៨ | បើមិនបានទៅពិនិត្យសុខភាព តើហេតុអ្វី?<br>គិតថាមិនចាំបាច់<br>ផ្ទះឆ្ងាយពីមណ្ឌលសុខភាព<br>រវល់គ្មានពេលទៅ<br>ផ្សេងៗ............................................. | <br>១<br>២<br>៣<br>៤ |
| ៥.៩ | តើអ្នកបានទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីត១៩ដែរឬទេ?<br>បានចាក់<br>មិនបានចាក់ | <br>១<br>២ (បើទេ សូមរំលងសំនួរ ៥.១០) |
| ៥.១០ | បើបាន,តើបានប៉ុន្មានលើក?<br>១លើក<br>២លើក<br>៣លើក | <br>១<br>២<br>៣ |
| ៥.១១ | បើមិនបានចាក់ តើហេតុអ្វី?<br>ខ្វះព័ត៌មានចាក់វ៉ាក់សាំង<br>រវល់ពេក<br>កត្តាសុខភាពផ្ទាល់ខ្លួន<br>ខ្លាចគ្រោះថ្នាក់ | <br>១<br>២<br>៣<br>៤ |

## ៦. ព័ត៌មានសំរាប់ការអប់រំ

| | | |
|---|---|---|
| ៦.១ | ចំនួនក្មេងអាយុពី៣ដល់៥ឆ្នាំនៅក្នុងគ្រួសារ?<br>មាន<br>គ្មាន | <br>១<br>២ (បើគ្មាន សូមរំលងសំនួរ ៦.២ & ៦.៣ ) |
| ៦.២ | បើមាន តើមានប៉ុន្មាននាក់? | សរុប:.........<br>ស្រី:.............. |
| ៦.៣ | តើក្នុងចំណោមក្មេងអាយុពី៣ដល់៥ឆ្នាំខាងលើមានបានចូលរៀនថ្នាក់មត្តេយ្យដែរឬទេ?<br>បានចូលទាំងអស់<br>បានចូលខ្លះ<br>មិនបានចូលទេ | <br>១ (សូមរំលងសំនួរ ៦.៤)<br>២<br>៣ |
| ៦.៤ | មិនបានចូលថ្នាក់មត្តេយ្យ មូលហេតុអ្វី?<br>គាត់នៅតូចពេក<br>រវល់ពេកមិនមានពេលជូនទៅសាលា<br>ផ្ទះស្ថិតនៅឆ្ងាយពីសាលាពេក<br>មិនមានថវិការបង់ថ្លៃសាលា<br>រង់ចាំដល់អាយុ៦ឆ្នាំបានអោយចូល<br>ផ្សេងទៀត:............................... | <br>១<br>២<br>៣<br>៤<br>៥<br>៦ |
| ៦.៥ | ចំនួនក្មេងអាយុពី៦ដល់១១ឆ្នាំនៅក្នុងបន្ទុកគ្រួសារ?<br>មាន<br>គ្មានទេ | <br>១<br>២ (បើទេ, សូមរំលងសំនួរ ៦.៦ ,៦.៧ & ៦.៨) |
| ៦.៦ | បើមានចំនួនប៉ុន្មាននាក់? | សរុប:............<br>ស្រី:............ |
| ៦.៧ | ចំនួនក្មេងអាយុពី៦ដល់១១ឆ្នាំដែលបានចូលរៀនសាលាបឋមសិក្សា?<br>បានចូលទាំងអស់គ្នា<br>បានចូលតែឈប់ទៅវិញហើយ<br>មិនបានចូលរៀនទេ | ១ (បើបាន, សូមរំលងសំនួរទី៦.៩)<br>២ ចំនួន........ស្រី........(បើឈប់, សូមរំលងសំនួរទី ៦.៨)<br>៣ ចំនួន........ស្រី........ (បើទេ, សូមរំលងសំនួរទី ៦.៨) |
| ៦.៨ | បើបានចូលរៀនតើចូលសាលាណាមួយ?<br>សាលារដ្ឋ<br>សាលាឯកជន<br>សាលាគាំទ្រដោយអង្គការ | <br>១ ចំនួន.........ស្រី.........<br>២ ចំនួន.........ស្រី.........<br>៣ ចំនួន.........ស្រី......... |

| | | |
|---|---|---|
| ៦.៩ | មូលហេតុដែលមិនបានចូលរៀនឬឈប់រៀន?<br>គ្មានលុយបង់ថ្លៃសាលា<br>គ្មានលុយអោយទៅរៀន<br>អោយនៅផ្ទះជួយធ្វើការគ្រួសារ<br>ប្រកបរបរចិញ្ចឹមគ្រួសារ<br>រៀនមិនទាន់គេ<br>ផ្សេងទៀត:…………………………………….. | ១<br>២<br>៣<br>៤<br>៥<br>៦ |
| ៦.១០ | ចំនួនក្មេងអាយុពី១២ដល់១៤ឆ្នាំនៅក្នុងបន្ទុកគ្រួសារ?<br>មាន<br>មិនមាន | ១<br>២ (បើគ្មាន, សូមចូលទៅចំនុចទី ៧ ) |
| ៦.១១ | បើមានប៉ុន្មាននាក់? | សរុប...........<br>ស្រី................. |
| ៦.១២ | តើក្មេងអាយុ១២ដល់១៤ឆ្នាំទាំងនេះបានចូលរៀនសាលាឫអនុវិទ្យាល័យដែរឬទេ?<br>បានចូលទាំងអស់<br>បានចូលតែបោះបង់វិញហើយ<br>មិនបានចូលរៀនទេ | ១ (សូមចូលទៅចំណុចទី ៧)<br>២ ចំនួន…………..ស្រី………<br>៣ ចំនួន…………ស្រី……… |
| ៦.១៣ | បើមិនបានចូលរៀនឬឈប់រៀនដោយសារមូលហេតុអ្វី?<br>គ្មានលុយបង់ថ្លៃសាលា<br>គ្មានលុយអោយទៅរៀន<br>អោយនៅផ្ទះជួយធ្វើការក្រុសារ<br>ប្រកបរបរចិញ្ចឹមគ្រួសារ<br>រៀនមិនទាន់គេ | ១ ចំនួន…………..ស្រី………<br>២ ចំនួន…………..ស្រី………<br>៣ ចំនួន…………..ស្រី………<br>៤ ចំនួន…………..ស្រី………<br>៥ ចំនួន…………..ស្រី……… |

## ៧. សមាជិកគ្រួសារ&ក្មេងដែលងាយរងគ្រោះនៅក្នុងបន្ទុក

| | | |
|---|---|---|
| ៧.១ | នៅក្នុងគ្រួសារនេះមានក្មេងដែលកំពុងធ្វើការនៅក្នុងស្ថានភាពងាយរងគ្រោះខ្លាំងដែរឬទេ?<br>(ការងារធ្ងន,ការងារពេលយប់,គ្មានពេលសំរាក,តំបន់គ្រោះថ្នាក់)<br>មាន<br>គ្មានទេ | ១<br>២ (បើទេ, ត្រូវរំលងសំនួរ ៧.២) |
| ៧.២ | បើមានតើគាត់កំពុងធ្វើប្រភេទការងារអ្វី?<br>(សរសេរចំ.) | |

| | | |
|---|---|---|
| ៧.៣ | មានកុមារកំព្រាឬកុមារដែលត្រូវគេបោះបង់កំពុងរស់នៅក្នុងគ្រួសារនេះដែរឬទេ?<br>មាន<br>គ្មានទេ | ១ ចំនួន...........ស្រី.........<br>២ |
| ៧.៤ | នៅក្នុងគ្រួសារនេះមានក្មេងដែលកំពុងប្រឈមនិងបញ្ហាកង្វះចំណីអាហារដែរឬទេ?<br>(ស្គាំងស្គម ចុងសក់ក្រហម ពោះធំ)<br>មាន<br>គ្មានទេ | ១ ចំនួន...........ស្រី.........<br>២ |
| ៧.៥ | នៅក្នុងគ្រួសារនេះមានក្មេងដែលមានភាពពិការខួរក្បាលឬពិការផ្នែករាងកាយដែរឬទេ?<br>មាន<br>គ្មានទេ | ១ ចំនួន...........ស្រី.........<br>២ |
| ៧.៦ | តើក្នុងសហគមន៍នេះធ្លាប់ឃើញមានអ្នកប្រើប្រាស់គ្រឿងញៀនដែរឬទេ?<br>ធ្លាប់<br>មិនធ្លាប់ | ១<br>២ (បើទេ, សូមរំលងសំនួរ៧.៧) |
| ៧.៧ | បើមានតើគាត់ធ្លាប់បានបង្ករបញ្ហាអ្វីខ្លះក្នុងសហគមន៍? | |
| ៧.៨ | នៅក្នុងគ្រួសារនេះមានសមាជិកណាម្នាក់ដែលកំពុងមានជម្ងឺរ៉ាំរ៉ៃដែរឬទេ?<br>មាន<br>គ្មានទេ | ១ ចំនួន...........ស្រី.........<br>២ (បើទេ, សូមរំលងសំនួរ៧.៩) |
| ៧.៩ | បើមានតើគាត់មានបានទទួលការគាំពារថែរទាំសុខភាពឬការព្យាបាលដែរឬទេ?<br>មាន<br>គ្មានទេ | ១ ចំនួន......ស្រី... (បើមាន, សូមរំលងសំនួរ ៧.១០)<br>២ |
| ៧.១០ | បើគ្មានហេតុអ្វី?<br>ជរាពេកមិនត្រូវការព្យាបាលទេ<br>មិនដឹងកន្លែងដែលត្រូវទៅព្យាបាល<br>មិនមានសេវាកម្មជួយគាត់ទេ<br>មិនមានប្រាក់សំរាប់ចេញថ្លៃព្យាបាល<br>ផ្សេងៗ........................ | ១<br>២<br>៣<br>៤<br>៥ |

| | | |
|---|---|---|
| ៧.១១ | តើគ្រួសារអ្នកមានបានទទួលប័ណ្ណក្រីក្រដែរឬទេ?<br>មាន<br>មិនមានទេ | <br>១<br>២ (បើទេ, សូមរំលងសំនួរ ៧.១២ & ៧.១៣) |
| ៧.១២ | បើមានតើផ្តល់ដោយនរណា?<br>អាជ្ញាធរឃុំសង្កាត់<br>អង្គការក្រៅរដ្ឋាភិបាល<br>មិនដឹង | <br>១<br>២<br>៣ |
| ៧.១៣ | តើអ្នកទទួលបានផលប្រយោជន៍អ្វីខ្លះពីប័ណ្ណនេះ? | |
| ៧.១៤ | តាមការយល់ឃើញ របស់អ្នកតើអ្នកក្រីក្រក្នុងសហគមន៍បានទទួលប័ណ្ណក្រីក្រ គ្រប់ឬទេ?<br>គ្រប់<br>មិនគ្រប់<br>មិនដឹង | <br>១<br>២<br>៣ |
| ៧.១៥ | តើគ្រួសារអ្នកមានជាប់បំណុលដែរឬទេនៅពេលនេះ?<br>មាន<br>មិនមានទេ | <br>១<br>២ (បើគ្មាន, សូមចូលទៅចំនុចទី ៨ ) |
| ៧.១៦ | បើមានតើខ្ចីយកមកធ្វើអ្វី?<br>ធ្វើដើមទុនរប្រកបរបរ<br>សំរាប់ព្យាបាលជម្ងឺ<br>សំរាប់ស្ត្រីឆ្លងទន្លេ<br>សំរាប់បង់លុយអោយកូនរៀន<br>ទិញស្បៀងសំរាប់គ្រាអាសន្នក្នុងគ្រួសារ<br>សាងសង់លំនៅដ្ឋាន<br>ទិញសម្ភារះប្រើប្រាស់ក្នុងផ្ទះ<br>ផ្សេងទៀត........................................... | <br>១<br>២<br>៣<br>៤<br>៥<br>៦<br>៧<br>៨ |
| ៧.១៧ | តើអ្នកនឹងមានលទ្ធភាពសង់ប្រាក់នេះវិញបានឬទេ?<br>សងបាន<br>ពិបាកសង<br>មិនមានលទ្ធភាពសង | <br>១<br>២<br>៣ |

## ៨. អនាម័យផ្ទាល់ខ្លួននិងអនាម័យទូទៅ

| | | |
|---|---|---|
| ៨.១ | ក្នុងគ្រួសារនេះមានបង្គន់ ប្រើប្រាស់ដែឬទេ?<br>មាន<br>គ្មានទេ | <br>១(បើមាន,ត្រូវរំលងសំនួរ ៨.៣)<br>២ (បើគ្មាន, ត្រូវរំលងសំនួរ ៨.៣) |
| ៨.២ | បើមានតើជាប្រភេទបង្គន់អ្វី?<br>បង្គន់អនាម័យ<br>បង្គន់បណ្តោះអាសន្ន | <br>១<br>២ |
| ៨.៣ | បើគ្មានតើទៅបន្ទោរបង់នៅកន្លែងណា?<br>ប្រើបង្គន់សាធារណៈ<br>ប្រើបង្គន់របស់អ្នកជិតខាងឬបងប្អូន<br>ប្រើបង្គន់ជួល<br>ទៅគម្ពោតព្រៃនៅជិតផ្ទះ/ទៅវាល/លើទឹក | <br>១<br>២<br>៣<br>៤ |
| ៨.៤ | ប្រភពទឹកប្រើប្រាស់ក្នុងគ្រួសារសំរាប់ទទួលទាននិងចម្អិនអាហារ?<br>ទឹកស្អាតរបស់រដ្ឋ<br>ទឹកភ្លៀង<br>ទឹកស្ទឹង<br>ទិញទឹកពីឡាន<br>ទឹកក្នុងបឹងទន្លេឬស្រះ<br>ទឹកស្អាតអណ្តូងក្រោមដី<br>ទឹកអណ្តូងលូចំហរ<br>ផ្សេងទៀត:................................ | <br>១<br>២<br>៣<br>៤<br>៥<br>៦<br>៧<br>៨ |
| ៨.៥ | ប្រភពទឹកសំរាប់បោកគក់សំលៀលបំពាក់និងមុជ<br>សំរាប់គ្រួសារ?<br>ទឹកស្អាតរបស់រដ្ឋ<br>ទឹកភ្លៀង<br>ទឹកស្ទឹង<br>ទិញទឹកពីឡាន<br>ទឹកក្នុងបឹង ទន្លេឬស្រះ<br>ទឹកស្អាតអណ្តូងក្រោមដី<br>ទឹកអណ្តូងលូចំហរ<br>ផ្សេងទៀត:................................ | <br><br>១<br>២<br>៣<br>៤<br>៥<br>៦<br>៧<br>៨ |

| | | |
|---|---|---|
| ៨.៦ | តើអ្នកយល់ឃើញយ៉ាងណាដែរចំពោះគុណភាពទឹកដែលអ្នកកំពុងប្រើប្រាស់បច្ចុប្បន្ន?<br>ទឹកស្អាតមានអនាម័យល្អ ១<br>ស្អាតមធ្យមអាចប្រើប្រាស់បាន ២<br>មិនស្អាតទេ ៣<br>មិនដឹង ៤ | |
| ៨.៧ | ទឹកដែលគ្រួសារអ្នកប្រើសំរាប់ទទួលទានបច្ចុប្បន្ន?<br>ទឹកដាំឆ្អិន ១<br>ទឹកបរិសុទ្ធដប ២<br>ទឹកពីធុងចំរោះ ៣<br>ទឹករដ្ឋផ្ទាល់ ៤<br>ទឹកភ្លៀង ៥<br>ទឹកទន្លេ ៦ | |
| ៨.៨ | ស្ថានភាពទឹកជំនន់ក្នុងលំនៅដ្ឋាន?<br>មិនដែលលិច ១<br>លិចម្តងម្កាល ២<br>លិចញឹកញាប់ ៣ | |
| ៨.៩ | បើលិច រយៈពេលប៉ុន្មាន?<br>ក្រោយភ្លៀងរួចស្រក់វិញ ១<br>តិចជាង ១ សប្តាហ៍ ២<br>ពី ១ សប្តាហ៍ទៅ ១ខែ ៣<br>លើសពី ១ ខែ ៤ | |

## ៩.ទ្រព្យសម្បត្តិជាកម្មសិទ្ធគ្រួសារ

| | | |
|---|---|---|
| ៩.១ | មធ្យោបាយធ្វើដំណើរក្នុងគ្រួសារប្រចាំថ្ងៃ?<br>រថយន្តផ្ទាល់ខ្លួន ១<br>ម៉ូតូផ្ទាល់ខ្លួន ២<br>រម៉កឬម៉ូតូកង់បីផ្ទាល់ខ្លួន ៣<br>កង់ផ្ទាល់ខ្លួន ៤<br>គ្មាន ៥<br>ផ្សេងទៀត ............................... ៦ | |

| | | |
|---|---|---|
| ៩.២ | សម្ភារៈប្រើប្រាស់សំរាប់ទំនាក់ទំនងដែលមាននៅក្នុងគ្រួសារ?សូមជ្រើសរើស?<br>ទូរទស្សន៍ ១<br>វិទ្យុ ២<br>ទូរស័ព្ទដៃម៉ូតចាស់ ៣<br>ស្មាតហ្វូន ៤<br>ផ្សេងទៀត .................................. ៥ | |

## ១០. ការប្រើប្រាស់ភ្លើងអគ្គីសនី

| | | |
|---|---|---|
| ១០.១ | ភ្លើងបំភ្លឺសំរាប់ប្រើប្រាស់ក្នុងគ្រួសារ?<br>ភ្ជាប់ភ្លើងរដ្ឋផ្ទាល់ ១<br>ភ្ជាប់ភ្លើងរដ្ឋតាមរយៈផ្ទះអ្នកជិតខាង ២<br>ប្រើម៉ាស៊ីនភ្លើងឯកជនក្នុងភូមិ ៣<br>ប្រើម៉ាស៊ីនភ្លើងផ្ទាល់ខ្លួន ៤<br>ប្រើភ្លើងចង្កៀង ៥<br>អាគុយ ៦<br>ថាមពលព្រះអាទិត្យ(សូឡា) ៧ | |

## ១១. ប្រភពថាមពលសំរាប់ចំអិនអាហារ

| | | |
|---|---|---|
| ១១.១ | ប្រភពថាមពលសំរាប់ចំអិនអាហារ?<br>ប្រើឆ្នាំខ្សែភ្លើង ១<br>ប្រើហ្គាស ២<br>ប្រើអុសឈើ ៣<br>ប្រើធ្យូង ៤ | |

## ១២. ស្ថានភាពនៃការរស់នៅក្នុងសហគមន៍

| | | |
|---|---|---|
| ១២.១ | ការរស់នៅក្នុងសហគមន៍ជួបប្រទះបញ្ហាអ្វីខ្លះ? | |

**សូមអរគុណ!**



អង្គការសមាគមធាងត្នោត

Sahmakum Teang Tnaut Organization • a Cambodian Urban NGO

Tel: (855) 23 555 1964
Website: www.teangtnaut.org
UV:https://urbanvoicecambodia.net
Facebook:https://www.facebook.com/sttcambodia